ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

FUTABA MICROFINANCE PLC.



# របាយការណ៍ប្រចាំឆ្នាំ | ២០២២

# មាតិកា ២០២២


០៣ សាខាខណ្ឌព្រែកព្នៅ
០៤ ផែនទីតំបន់ប្រតិបត្តិការ
០៥ ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល
០៧ ចំណាប់អារម្មណ៍របស់នាយកប្រតិបត្តិ

## ០១ សមិទ្ធផលសំខាន់ៗ

លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ ១០
សមិទ្ធផលប្រតិបត្តិការសំខាន់ៗ ១១
លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស ១២

## ០២ អំពី ហ្វូតាបា

១៦ ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា
១៧ ប្រវត្តិសង្ខេបរបស់ ហ្វូតាបា
១៩ ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល
២០ ស្លាកសញ្ញារបស់ ហ្វូតាបា

## ០៣ អភិបាលកិច្ច

ម្ចាស់ភាគទុនិក និងដើមទុន ២២
រចនាសម្ព័ន្ធ ២៣
ក្រុមប្រឹក្សាភិបាល ២៤
គណៈគ្រប់គ្រង ២៦

## ០៤ ផលិតផល ហ្វូតាបា

៣២ ឥណទានអាជីវកម្ម
៣២ ឥណទានគេហដ្ឋាន
៣២ ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន
៣២ ឥណទានកសិកម្ម
៣៣ ឥណទានសិក្សា
៣៣ ឥណទានបុគ្គលិក
៣៣ ឥណទាននិយោជិត

## ០៥ សមិទ្ធផលអាជីវកម្ម

សមិទ្ធផលឥណទានតាមវិស័យ ៣៦
សមិទ្ធផលឥណទានតាមផលិតផល ៣៧
ចំណាត់ថ្នាក់ប្រភេទឥណទាន ៣៨
ចំណាត់ថ្នាក់ប្រភេទផលិតផល ៣៨

## ០៦ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

៤០ ការបណ្តុះបណ្តាលខាងក្នុង
៤១ ការបណ្តុះបណ្តាលខាងក្រៅ
៤១ សិក្ខាសាលាប្រចាំឆ្នាំ

## ០៧ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម ៤៤
សវនកម្មផ្ទៃក្នុង ៤៥

## ០៨ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មឯករាជ្យ

៤៨ របាយការណ៍ក្រុមប្រឹក្សាភិបាល
៥១ របាយការណ៍របស់សវនករឯករាជ្យ
៥៣ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
៥៤ របាយការណ៍លទ្ធផល
៥៥ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
៥៦ របាយការណ៍លំហូរសាច់ប្រាក់

## ០៩ ដៃគូសហប្រតិបត្តិការរបស់ ហ្វូតាបា

ដៃគូ ៥៧
ម្ចាស់កម្ចី ៥៧

# សាខាខណ្ឌព្រែកព្នៅ




រាល់ចម្ងល់ និងព័ត៌មានផ្សេងៗសូមទាក់ទងមកលេខ៖

០៧០ ៣៥៧ ៣៣៣ / ០៧០ ៣១២ ៣៣៣

ស្កេនត្រង់នេះដើម្បីស្វែងរកទីតាំងថ្មី

សូមអរគុណ !

# ផែនទីតំបន់ប្រតិបត្តិការ

### ១ ការិយាល័យកណ្ដាល និងសាខាការិយាល័យកណ្ដាល

អគារលេខ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(៨៥៥) ២៣ ២២៤ ៣៣៣ / (៨៥៥) ៧០ ៣១២ ៣៣៣

### ២ សាខាខណ្ឌព្រែកព្នៅ

#18A-B ផ្លូវលេខ៥ ភូមិដូង សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(៨៥៥) ៧០ ៣១៧ ៣៣៣

### ៣ សាខាខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ៧៨ក ផ្លូវជាតិលេខ៤ ភូមិព្រៃស្វាយ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ (៨៥៥) ៧០ ៣១៦ ៣៣៣

### ៤ សាខាក្រុងច្បារមន

ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ព្រះរាជាណាចក្រកម្ពុជា។

(៨៥៥) ៧០ ៣១៤ ៣៣៣




| ចំនួនខេត្តប្រតិបត្តិ | ចំនួនស្រុកប្រតិបត្តិ | ចំនួនឃុំប្រតិបត្តិ | ចំនួនភូមិប្រតិបត្តិ |
|---|---|---|---|
| ១០ ខេត្ត | ៤៤ ស្រុក | ១៥៥ ឃុំ | ៣៧៨ ភូមិ |

# ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



## លោក ទ្រឹក ផល្លី

ប្រធានក្រុមប្រឹក្សាភិបាល

តាមការព្យាករណ៍របស់ធនាគារពិភពលោកមើលឃើញថា សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបន្តងើបឡើង វិញនៅក្នុងឆ្នាំ២០២២ ដែលការងើបឡើងវិញលើវិស័យសេវាកម្មដែលមានភាពរឹងមាំ និងការជំរុញឱ្យមាន តម្រូវការខ្ពស់នៃអ្នកប្រើប្រាស់។ ហើយកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២៣ ត្រូវបានព្យាករណ៍ថានឹង ឈានដល់ ៥.២ ភាគរយ។ ដែលហានិភ័យនៃការធ្លាក់ចុះនេះ រួមមានការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃតម្រូវការខាងក្រៅ ការរឹតបន្តឹងផ្នែកហិរញ្ញវត្ថុសកល និងការធ្លាក់ចុះតម្លៃប្រេង។ ម៉្យាងវិញទៀត ការបើកដំណើរការឡើងវិញរបស់ប្រទេសចិន បង្ហាញពីឱកាសមួយសម្រាប់កម្ពុជាក្នុងការជំរុញឧស្សាហកម្ម ទេសចរណ៍ ការធ្វើដំណើរ និងការទាក់ទាញលំហូរវិនិយោគពីបរទេស។ ដំបូងឡើយមានការស្ទុះងើបឡើងវិញនៃផលិតកម្មដែលផ្តោតលើការនាំចេញ និងកត្តាជំរុញកំណើនវិស័យ សេវាកម្ម ដោយតម្រូវការអ្នកប្រើប្រាស់មានការកើនឡើង និងការត្រឡប់មកវិញនៃភ្ញៀវទេសចរបរទេស។ នេះជាការប៉ះប៉ូវនៃការធ្លាក់ចុះក្នុងពេលថ្មីៗនេះក្នុងការនាំចេញ ទំនិញរបស់កម្ពុជាដែលរងផលប៉ះពាល់ ដោយការធ្លាក់ចុះនៃតម្រូវការខាងក្រៅនានា។ ការប្រើប្រាស់ក្នុងស្រុកក៏កំពុងត្រូវបានជំរុញដោយ មានការបន្ធូរបន្ថយអតិផរណាដែលបានធ្លាក់ចុះមកត្រឹម ២.៩ ភាគរយ ក្នុងខែធ្នូ ឆ្នាំ ២០២២ ដោយសារតម្លៃថាមពល និងអាហារមានស្ថិរភាព។

ទន្ទឹមនឹងនេះ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះដោយសារតែឥទ្ធិពល នៃសង្គ្រាមរវាងរុស្ស៊ី-អ៊ុយក្រែនដែលបានអូសបន្លាយពេល និងការរីករាលដាលនៃមេរោគកូវីដកន្លងមកនោះ បានធ្វើឱ្យអតិផរណាមានការកើនឡើង និងការរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលកំពុងបន្ត។ ឆ្លើយតបនឹងស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជា បានផ្សព្វផ្សាយ

នូវយុទ្ធសាស្ត្រ និងដាក់ចេញនូវវិធានការ ក៏ដូចជាការដាក់បញ្ចូលនូវថវិកាជាតិ ដើម្បីកាត់បន្ថយអត្រាអតិផរណា និងរក្សាកំណើនសេដ្ឋកិច្ច នៅក្នុងឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់ទៀត។ លើសពីនេះ រដ្ឋាភិបាលក៏បានដាក់បញ្ចូលមូលនិធិដើម្បីជួយគាំទ្រ និងស្តារអាជីវកម្មខ្នាតតូច និងមធ្យម និងសកម្មភាពសេដ្ឋកិច្ច និងគ្រួសារក្រីក្រ និងជនងាយរងគ្រោះដែលរងផលប៉ះពាល់ដោយមេរោគកូវីដ។ តាមលទ្ធផលយន្តការទាំងនេះរបស់រាជរដ្ឋាភិបាលបានកាត់បន្ថយអត្រាអតិផរណាយ៉ាងមានប្រសិទ្ធភាព និងជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០២២។ យោងតាមមន្ត្រីជាន់ខ្ពស់នៃធនាគារជាតិនៃកម្ពុជាបានលើកឡើងថា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាបាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ជាពិសេសការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ។ រដ្ឋាភិបាលបានគាំទ្រវិស័យនេះ តាមរយៈការកំណត់ចក្ខុវិស័យដ៏ច្បាស់លាស់ និងយុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍ ដែលអាចឱ្យវិស័យនេះពង្រីកវិសាលភាពនៃប្រតិបត្តិការ របស់ខ្លួនប្រកបដោយនិរន្តរភាព និងទំនុកចិត្ត ក៏ដូចជាជួយបង្កើតឱកាសថ្មីសម្រាប់ការអភិវឌ្ឍន៍សេវាហិរញ្ញវត្ថុ សំដៅផ្តល់ជូនប្រជាជនកម្ពុជានូវសេវាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងភាពស្និតស្នាលបំផុត។ គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២២ ទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទមានប្រមាណ ៤៤,៤ ពាន់ពាន់លានរៀល (ស្មើនឹង ១០,៨ ពាន់លានដុល្លារ អាមេរិក) ក្នុងនោះកម្ចីសរុបមានប្រមាណជា ៣៨,៩ ពាន់ពាន់លានរៀល (ស្មើនឹង ៩,៥ ពាន់លានដុល្លារអាមេរិក) ដែលបានផ្តល់ជូនអតិថិជនជាង ២,១ លានគណនី នៃរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា។ ហើយសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានទឹកប្រាក់សរុបប្រមាណ ១៩,៤ ពាន់ពាន់លានរៀល (ស្មើនឹង ៤,៧ ពាន់លានដុល្លារអាមេរិក) ពីអ្នកដាក់ប្រាក់បញ្ញើប្រមាណ ២,៧ លាននាក់។ លទ្ធផលដែលទទួលបានរហូតមកដល់ពេលនេះ គឺបានមកពីការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា និងកិច្ចសហប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងការផ្តល់ប្រាក់កម្ចីជូនដល់អតិថិជនក្នុងការ ធ្វើអាជីវកម្ម និងផ្តល់ឥណទានរៀបចំឡើងវិញ ក៏ដូចជាការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋផងដែរ។ បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ធនាគារជាតិនៃកម្ពុជាបានបង្ហាញថា ធនាគារពាណិជ្ជមានចំនួន ៥៩ ធនាគារឯកទេសមានចំនួន ០៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន ០៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៨២ ប្រតិបត្តិករឥណទានជនបទមានចំនួន ២២៤ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានចំនួន ១៦ អ្នកដំណើរការតតិយភាគីមានចំនួន ០៥ គ្រឹះស្ថានផ្តល់សេវាទូទាត់មានចំនួន ៣៤ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជាមានចំនួន ០១ ការិយាល័យតំណាងធនាគារបរទេសមានចំនួន ០៦ និងអាជីវករប្តូរប្រាក់មានចំនួន ២.៨៦៩។ ចំណុចនេះយើងអាចមើលឃើញថា ទោះបីជាទទួលរងឥទ្ធិពលពីវិបត្តិ ក៏ប្រព័ន្ធធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅតែបន្តមានស្ថិរភាពរឹងមាំ និងភាពធន់ដោយមានការបន្តបណ្តាក់ទុនបន្ថែមពីអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកមកលើវិស័យនេះនៅកម្ពុជា។

ដោយសារតែមានផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដ និងបញ្ហាអូសបន្លាយនៃសង្គ្រាមរវាង ប្រទេសរុស្ស៊ី និងអ៊ុយក្រែន នៅឆ្នាំ២០២២ នេះ ក៏បានជះឥទ្ធិពលមួយចំនួនដែលបានធ្វើឱ្យកម្រិតហានិភ័យនៃផលបត្រឥណទានមានការកើនឡើងខ្ពស់របស់ស្ថាប័នហិរញ្ញវត្ថុមួយចំនួន រួមទាំងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផងដែរ។ ទោះជាស្ថិតនៅស្ថានភាពនៃការរីករាលដាលនៃមេរោគកូវីដនេះក៏ដោយក៏គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែអាចរក្សាប្រាក់ចំណេញរបស់ខ្លួនបានចំនួន ៤៤៩.៤២៦ ដុល្លារអាមេរិក ជាមួយនឹងទ្រព្យសកម្មចំនួន ១៥.៧៤៣.៧៨០ ដុល្លារអាមេរិក។ លទ្ធផលនេះបង្ហាញពីការចូលរួមសហការពីបុគ្គលិកគ្រប់ផ្នែក និងពិសេសផ្នែកឥណទានផ្ទាល់ ដែលបានខិតខំប្រឹងប្រែងក្នុងការគ្រប់គ្រង និងដោះស្រាយឱ្យបានទាន់ពេលវេលា។

ក្នុងនាមប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អតិថិជន ភាគទុនិកជប៉ុនរបស់យើងខ្ញុំ នៅតែមានសុច្ឆន្ទៈចូលរួមចំណែកអភិវឌ្ឍធនធានមនុស្សជំនាន់ក្រោយនៃព្រះរាជាណាចក្រកម្ពុជា នាយកប្រតិបត្តិ ជំនួយការនាយកប្រតិបត្តិ និងបុគ្គលិកទាំងអស់របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សម្រាប់ការគាំទ្រ និងការខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួន និងការអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន។ ជាពិសេសចំពោះធនាគារជាតិនៃកម្ពុជា និងដៃគូសហប្រតិបត្តិការ ដែលតែងតែផ្តល់ការសហការ និងការគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ ដើម្បីចាត់ចែងនូវរាល់សកម្មភាពការងារទាំងអស់ប្រកបដោយតម្លាភាពរហូតមកដល់ពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ វិបុលសុខ ចូរកើតមានដល់លោកអ្នក និងក្រុមគ្រួសារ នូវសេចក្តីចម្រើនមានបានជោគជ័យគ្រប់ភារកិច្ចការងារ ជានិច្ចនិរន្តតរៀងទៅ។



លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល

# ចំណាប់អារម្មណ៍របស់នាយកប្រតិបត្តិ



**លោក Junichi SASAKI**
នាយកប្រតិបត្តិ

ជូនចំពោះអតិថិជន និងដៃគូពាណិជ្ជកម្មជាទីគោរព!

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានទទួលអាជ្ញាប័ណ្ណជាស្ថាប័នហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបសកម្មភាពអាជីវកម្ម នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រង ព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគត របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍សម្រាប់ប្រកបអាជីវកម្ម ជាផ្លូវការមកឱ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ជំនួសឱ្យអាជ្ញាបណ្ណដែលមានកំណត់រយៈពេល ៣ឆ្នាំ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ គ្រឹះស្ថានបានបើកប្រតិបត្តិការការិយាល័យសាខាចំនួន ០៤ ដែលរួមទាំងទីស្នាក់ការកណ្តាល (រួមជាមួយសាខាការិយាល័យកណ្តាល) សាខាខណ្ឌព្រែកព្នៅ/ខណ្ឌទួលគោក សាខាខណ្ឌពោធិ៍សែនជ័យ និងសាខាក្រុងច្បារមន ជាមួយនឹងអតិថិជនដែលបាននឹងកំពុងប្រើប្រាស់ កម្ចីមានសរុប ៧៨៩នាក់ ស្មើនឹងផលបត្រឥណទានសរុប ១៣.២៩៥.៩២០ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងរបស់មន្ត្រីឥណទានចំនួន ២៦ នាក់។ នៅក្នុងអំឡុងឆ្នាំ២០២២ នេះ មានផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដ និងបញ្ហាសង្គ្រាម រវាង ប្រទេសរុស្ស៊ី និងអ៊ុយក្រែន អូសបន្លាយមកដល់ពេលនេះ បានធ្វើឱ្យការស្ទុះងើបឡើងនៃសេដ្ឋកិច្ចកម្ពុជាមានភាពយឺតយ៉ាវ។

ផលប៉ះពាល់នេះបានធ្វើឱ្យគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានអត្រាហានិភ័យផលបត្រឥណទានមានការកើនឡើងខ្ពស់ ប៉ុន្តែបើទោះជាស្ថិតក្នុងស្ថានភាពនេះក៏ដោយ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នៅតែអាចរក្សាប្រាក់ចំណេញរបស់ខ្លួនបានចំនួន ៤៤៩.៤២៦ ដុល្លារអាមេរិក។

ទោះបីគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មិនទាន់មានការិយាល័យប្រតិបត្តិការឱ្យបានទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា ក៏ចក្ខុវិស័យរបស់យើងខ្ញុំ ត្រូវតែខិតខំអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឈានមុខមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍ សង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ក្នុងពេលបច្ចុប្បន្ន ក៏ដូចពេលអនាគតតាមរយៈការធ្វើឱ្យមានលំនឹងស្ថិរភាព តម្លាភាពលើផ្នែកទីផ្សារហិរញ្ញវត្ថុនៅកម្ពុជា និងផែនការយុទ្ធសាស្ត្ររយៈពេលវែងដែលនឹងពង្រីកតំបន់ប្រតិបត្តិការឱ្យបានទូលំទូលាយបន្ថែមទៀតនៅតាមបណ្តាខេត្តផ្សេងៗទៀត ដែលជាបំណងប្រាថ្នាដ៏សុចរិត ក៏ដូចជាគោលដៅរបស់គ្រឹះស្ថានយើងខ្ញុំផងដែរ។

កន្លងមក ដើម្បីបំពេញតម្រូវការរបស់អតិថិជន គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតផលិតផលសេវាហិរញ្ញវត្ថុជាច្រើនដែលរួមមាន ឥណទានអាជីវកម្ម ឥណទានកសិកម្ម ឥណទានគេហដ្ឋាន ឥណទានសម្រាប់ប្រើប្រាស់ ឥណទានបុគ្គលិក ឥណទានសម្រាប់ការសិក្សា និងឥណទាននិយោជិត។ ចំពោះឥណទានបុគ្គលិក និងឥណទានសម្រាប់ការសិក្សា ត្រូវបានផ្តល់ជូនក្នុងអត្រាការប្រាក់ទាបបំផុត ជាមួយនឹងសេវាល្អឥតខ្ចោះដែលមិនធ្លាប់មានក្នុងគោលដៅចូលរួមលើកស្ទួយផ្នែកសង្គម គាំទ្រជីវភាពគ្រួសាររបស់បុគ្គលិក និងអភិវឌ្ឍនូវវិស័យធនធានមនុស្ស។ គ្រឹះស្ថានរបស់យើងខ្ញុំ នឹងរិះរកវិធីក្នុងការផ្តល់ជូននូវសេវាដ៏សម្បូរបែប និងប្រកបដោយភាពច្នៃប្រឌិតខ្ពស់លើដំណោះស្រាយហិរញ្ញវត្ថុថ្មីៗ ជូនចំពោះអតិថិជនចាស់ និងថ្មីទាំងអស់។

ទន្ទឹមនឹងការបំពេញតម្រូវការអតិថិជន យើងក៏បានយកចិត្តទុកដាក់លើការពង្រឹងប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ខ្លួន ដើម្បីឱ្យការប្រតិបត្តិមានភាពរឹងមាំដោយផ្តោតលើការបណ្តុះបណ្តាលចំណេះជំនាញបុគ្គលិក ការកែសម្រួលរចនាសម្ព័ន្ធ និងបច្ចុប្បន្នភាពលើគោលការណ៍នីតិវិធីនានា ព្រមទាំងត្រូវប្រតិបត្តិតាមច្បាប់ ឬបទប្បញ្ញត្តិដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា និងក្រសួងពាក់ព័ន្ធ។

ដោយសារតែរដ្ឋាភិបាលបានអនុញ្ញាតឱ្យអាជីវកម្មចាប់ផ្តើមបើកដំណើរឡើងវិញ និងស្ថានភាពធូរស្រាលច្រើននៃការរីករាលដាលមេរោគកូវីដ ដែលបានធ្វើឱ្យសេដ្ឋកិច្ចក្នុងស្រុករបស់កម្ពុជានឹងវិលទៅរកភាពប្រក្រតីវិញនូវមុខរបរ និងអាជីវកម្មនានាមានដំណើការល្អប្រសើរឡើងវិញ រួមទាំងការធ្វើដំណើរ និងទេសចរណ៍ផងដែរសម្រាប់ឆ្នាំ២០២២។ ម៉្យាងទៀត យើងសង្ឃឹម និងជឿជាក់ថា គ្រឹះស្ថានយើងខ្ញុំនឹងក្លាយជាមាគ៌ា សម្រាប់អ្នកជំនាន់ក្រោយកម្ពុជា ដែលសម្រេចយកភាពត្រឹមត្រូវស្មើគ្នា និងរក្សាឱ្យបាននូវតម្លាភាព ជាមូលដ្ឋានក្នុងវិស័យសេវាហិរញ្ញវត្ថុ។ គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានការគាំទ្រមូលនិធិពីភាគទុនិកឯកកម្មសិទ្ធិនៃប្រទេសជប៉ុន ដែលយើងខ្ញុំអាចចាត់ចែងប្រកបដោយភាពស្ទាត់ជំនាញ និងផ្តល់សេចក្តីសម្រេចចិត្តបានយ៉ាងឆាប់រហ័ស ដើម្បីបំពេញតាមតម្រូវការអតិថិជន។

ដើម្បីឱ្យ “សុបិនអតិថិជនក្លាយជាការពិត” យើងខ្ញុំរីករាយស្វាគមន៍សហការក្នុងការផ្តល់សេវាហិរញ្ញវត្ថុយ៉ាងកក់ក្តៅ និងជាទីទុកចិត្តបំផុតជូនអតិថិជនទាំងអស់ និងគ្រប់ពេលវេលាដែលត្រូវការ។

ជាទីបញ្ចប់ ក្នុងនាមថ្នាក់ដឹកនាំគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ខ្ញុំសូមថ្លែងអំណរគុណដល់អតិថិជន ភាគទុនិកជប៉ុន ក្រុមប្រឹក្សាភិបាល ជំនួយការនាយកប្រតិបត្តិ និងបុគ្គលិកទាំងអស់ ដែលតែងតែគាំទ្រ និងការខិតខំប្រឹងប្រែង ក្នុងការអនុវត្តតាមផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថានកន្លងមក ក៏ដូចជាធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់ការសហការ និងការគាំទ្រដល់គ្រឹះស្ថានយើងខ្ញុំ។

សូមសុបិនរបស់លោកអ្នកក្លាយជាការពិត។



លោក Junichi SASAKI
នាយកប្រតិបត្តិ

# ០១ សមិទ្ធផលសំខាន់ៗ

- លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ
- សមិទ្ធផលប្រតិបត្តិការសំខាន់ៗ
- លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស

# លទ្ធផលសង្ខេបផ្នែកហិរញ្ញវត្ថុ

| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ដុល្លារអាមេរិក) | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | | | |
| សាច់ប្រាក់ក្នុងដៃ និងសាច់ប្រាក់នៅធនាគារ | ៦៤៧.៤៧៧ | ១.៦៨៧.០៨៧ | ២.១៧០.៥៥៧ |
| សមតុល្យប្រាក់កម្ចីសរុប | ១៤.២៣៨.៩៥៩ | ១៣.៣៨៧.៥៣៤ | ១៣.២៩៥.៩២០ |
| ទ្រព្យសម្បត្តិ និងឧបករណ៍-សម្ភារៈសរុប | ១០៧.០៦៨ | ៨៤.០៦៤ | ៩៨.៣៨១ |
| ទ្រព្យសម្បត្តិផ្សេងៗ | ១៣០.៨៤២ | ១៧២.៤១១ | ១៧៨.៩២២ |
| **សរុបទ្រព្យសកម្ម** | **១៥.១២៤.៣៤៦** | **១៥.៣៣១.០៩៦** | **១៥.៧៤៣.៧៨០** |
| បំណុល | | | |
| បំណុលផ្សេងៗ និងសំវិធានធន | ១.៥៤១.៥៤៩ | ១.៦៦១.៨៤៧ | ១.៦៣៦.២១៦ |
| កម្ចីរយៈពេលវែង និងកម្ចីរយៈពេលខ្លី | ៥.៥៣០.៥១៣ | ៥.១៥៨.២៩៣ | ៥.១៤៧.១៨២ |
| **បំណុលសរុប** | **៧.០៧២.០៦២** | **៦.៨២០.១៤០** | **៦.៧៨៣.៣៩៨** |
| មូលធនភាគទុនិក | | | |
| ដើមទុន | ៧.០០០.០០០ | ៧.០០០.០០០ | ៧.០០០.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៣០០.៨៥៦ | ៤៧៤.២៥២ | ៧៩៨.៧៤៩ |
| ប្រាក់ចំណេញរក្សាទុក | ៧៥១.៤២៨ | ១.០៣៦.៧០៤ | ១.១៦១.៦៣៣ |
| មូលធនសរុប | ៨.០៥២.២៨៤ | ៨.៥១០.៩៥៦ | ៨.៩៦០.៣៨២ |
| **សរុបបំណុល និងមូលធនភាគទុនិក** | **១៥.១២៤.៣៤៦** | **១៥.៣៣១.០៩៦** | **១៥.៧៤៣.៧៨០** |

| របាយការណ៍លទ្ធផលពេញលេញ (ដុល្លារអាមេរិក) | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| ចំណូលការប្រាក់ និងថ្លៃសេវាផ្សេងៗ | ១.៨២៣.០៦៩ | ១.៧៦៣.៣៦៦ | ១.៩៥៤.០៣១ |
| ចំណាយប្រតិបត្តិការ | ១.៣៤៦.០០៧ | ១.៣០៤.៦៩៤ | ១.៥០៤.៦០៥ |
| **ប្រាក់ចំណេញសុទ្ធ** | **៤៧៧.០៦២** | **៤៥៨.៦៧២** | **៤៤៩.៤២៦** |

| សូចនាករសំខាន់ៗ (ដុល្លារអាមេរិក) | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| អនុបាតសោធនភាព | ៥៥% | ៥៧% | ៥៩% |
| ប្រាក់ចំណេញសុទ្ធ ធៀបមធ្យមភាគទ្រព្យសកម្ម (RoA) | ៣% | ៣% | ៣% |
| ប្រាក់ចំណេញសុទ្ធ ធៀបមធ្យមភាគមូលធន (RoE) | ៦% | ៥% | ៥% |

# សមិទ្ធផលប្រតិបត្តិការសំខាន់ៗ

| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ (ដុល្លារអាមេរិក) | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| ចំនួនការិយាល័យសាខា | ៤ | ៤ | ៤ |
| ចំនួនខេត្តប្រតិបត្តិការ | ១១ | ១០ | ១០ |
| ចំនួនស្រុកប្រតិបត្តិការ | ៤២ | ៣៦ | ៤៤ |
| ចំនួនឃុំប្រតិបត្តិការ | ១៥៩ | ១៤៨ | ១៥៥ |
| ចំនួនភូមិប្រតិបត្តិការ | ៣៦៥ | ៣៤៨ | ៣៧៨ |
| ចំនួនបុគ្គលិកសរុប | ៧៧ | ៨៣ | ៩០ |
| ចំនួនមន្ត្រីឥណទាន | ១៩ | ២១ | ២៦ |
| មន្ត្រីឥណទានធៀបនឹងបុគ្គលិកសរុប | ២៥% | ២៥% | ២៩% |
| ចំនួនអតិថិជនសកម្ម | ៧០៩ | ៦៧៨ | ៧០៧ |
| ចំនួនគណនីឥណទានសកម្ម | ៨០០ | ៧៥១ | ៧៨៩ |
| ចំនួនគណនីឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ | ៤២ | ៣៦ | ៣០ |
| សំពៀតឥណទានសរុប (ដុល្លារអាមេរិក) | ១៤.៤០៩.២១៩ | ១៣.៣៨៧.៥៣៤ | ១៣.២៩៥.៩២០ |
| សំពៀតឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ (ដុល្លារអាមេរិក) | ៧៥៨.៣៨០ | ៦៣៧.៥០២ | ៥១១.៣៨២ |
| សំពៀតឥណទានជាមធ្យមក្នុងបុគ្គលិកម្នាក់ (ដុល្លារអាមេរិក) | ១៨៧.១៣៣ | ១៦១.២៩៦ | ១៤៧.៧៣២ |
| ទំហំឥណទានជាមធ្យម (ដុល្លារអាមេរិក) | ១៨.០១២ | ១៧.៨២៦ | ១៦.៨៥២ |
| ហានិភ័យឥណទានធំជាង ៣០ថ្ងៃ | ៤,៨០% | ៧,២៨% | ១២,៦២% |
| អនុបាតឥណទានលុបចេញពីបញ្ជី (ដុល្លារអាមេរិក) | ៣៨.៣៥៤ | - | ៣,៧៧៦ |

## សង្ខេបទិន្នន័យ ២០២២

| សំពៀតឥណទានសរុប | សំពៀតឥណទានជាមធ្យមក្នុងមន្ត្រីឥណទានម្នាក់ | សំពៀតឥណទានជាមធ្យមក្នុងបុគ្គលិកម្នាក់ |
|---|---|---|
| **១៣.២៩៥.៩២០** ដុល្លារអាមេរិក | **៥១១.៣៨២** ដុល្លារអាមេរិក | **១៤៧.៧៣២** ដុល្លារអាមេរិក |

| ទំហំឥណទានជាមធ្យម | ហានិភ័យឥណទានធំជាង ៣០ថ្ងៃ | អនុបាតឥណទានលុបចេញពីបញ្ជី |
|---|---|---|
| **១៦.៨៥២** ដុល្លារអាមេរិក | **១២,៦២** % | **៣,៧៧៦** ដុល្លារអាមេរិក |

# លទ្ធផលសង្ខេបផ្នែកធនធានមនុស្ស

ភាពរីកចម្រើនប្រកបដោយបរិយាប័ននៃវិស័យធនាគារ និងហិរញ្ញវត្ថុ គឺជាផ្នែកមួយនៃកម្លាំងចលករដ៏សំខាន់ ដែលបានចូលរួមលើកស្ទួយ ការអភិវឌ្ឍន៍វិស័យធនធានមនុស្សក្នុងប្រទេសកម្ពុជា ឱ្យមានភាពកាន់តែប្រសើរឡើង។ ជាក់ស្តែងក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះធនាគារពាណិជ្ជធំៗ ក៏ដូចជាស្ថាប័នមីក្រូហិរញ្ញវត្ថុនានា បានពង្រីកសាខារបស់ខ្លួនជាបន្តបន្ទាប់នៅទូទាំងព្រះរាជាណាចក្រ កម្ពុជា នាំឱ្យតម្រូវការធនធានមនុស្សក្នុងវិស័យនេះមានសន្ទុះកើនឡើងយ៉ាងខ្លាំងក្លា ដែលបានបង្កើនឱកាសការងារថ្មីៗ សម្រាប់អ្នកមានសមត្ថភាពផងដែរ។ ចរន្តនៃការផ្លាស់ប្តូរការងារពីកន្លែងមួយទៅកន្លែងមួយទៀតរបស់បុគ្គលិក បានដាក់សម្ពាធបន្ថែមទៀតដល់ស្ថាប័ននីមួយៗក្នុងការរៀបចំគោលនយោបាយប្រកួតប្រជែង ដើម្បីស្រូបទាញធនធានមនុស្សល្អៗ មានសក្តានុពលឱ្យមកបំពេញការងារក្នុងស្ថាប័នរៀងៗខ្លួន។
ទោះជាយ៉ាងណា ថ្នាក់ដឹកនាំគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានយល់ច្បាស់អំពីបញ្ហានេះ ហើយបានដាក់ចេញនូវយុទ្ធសាស្រ្តថ្មីៗប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ដោយផ្តោតការយកចិត្តទុកដាក់ខ្ពស់លើគុណតម្លៃរបស់បុគ្គលិក និងជំរុញលើកទឹកចិត្តដ៏ត្រឹមត្រូវចំពោះបុគ្គលិកឆ្នើម ក៏ដូចជាការិយាល័យសាខាឆ្នើមរបស់ ហ្វូតាបា ហើយរក្សាបាននូវធនធានមនុស្សល្អៗ រួមមានបុគ្គលិកកំពុងបម្រើការងារ និងបុគ្គលិកចូលថ្មីបន្ថែមទៀត។
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ស្ថិតិបុគ្គលិករបស់ ហ្វូតាបា មានចំនួនសរុប ៩០រូប (បុរស ៦៤រូប និង ស្រ្តី ២៦រូប) មានការកើនឡើងចំនួន ០៧រូប ធៀបទៅនឹងឆ្នាំ២០២២។

ខាងក្រោមនេះគឺជាទិន្នន័យបុគ្គលិកសង្ខេបរបស់ ហ្វូតាបា៖

### បុគ្គលិកសរុប និងប្រភេទ



បុគ្គលិកសរុប

៩០ នាក់,
១០០%





បុគ្គលិកគាំទ្រ

៦៤ នាក់,
៧១%

បុគ្គលិកលក់

២៦ នាក់,
២៩%

### ចំនួនបុគ្គលិកតាមសាខា



ការិយាល័យកណ្តាល

២៦ នាក់,
២៩%

សាខាការិយាល័យកណ្តាល

២៦ នាក់,
២៩%

សាខាខណ្ឌព្រែកព្នៅ

១០ នាក់,
១១%

សាខាខណ្ឌពោធិ៍សែនជ័យ

១២ នាក់,
១៣%

សាខាក្រុងច្បារមន

១៦ នាក់,
១៨%

## បម្រែបម្រួលបុគ្គលិកពេញមួយឆ្នាំ
(ឆ្នាំ ២០២២)




## កំណើនបុគ្គលិកចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២២





# ឥណទានគេហដ្ឋាន

**អតិថិជនគោលដៅ**

អតិថិជនដែលមានតម្រូវការសាច់ប្រាក់ដើម្បីទិញផ្ទះ ឬសាងសង់ផ្ទះសម្រាប់ស្នាក់នៅ និងប្រកបរបរអាជីវកម្ម។

**ប្រភេទរូបិយប័ណ្ណ**

ប្រាក់រៀល និង ដុល្លារ

**ទំហំឥណទាន**

២០០ ដុល្លារ - ២០០.០០០ ដុល្លារ

**រយៈពេលសង**

រហូតដល់ ១០ ឆ្នាំ

. សេវាកម្មរហ័ស ប្រកបដោយទំនុកចិត្តខ្ពស់
. ទទួលបានប្រាក់កម្ចីតាមតម្រូវការ
. អត្រាការប្រាក់ទាប និងលក្ខខណ្ឌឥណទានងាយស្រួល

# ០២ អំពី ហ្វូតាបា

- ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា
- ប្រវត្តិសង្ខេបរបស់ ហ្វូតាបា
- ទស្សនៈវិស័យ  បេសកកម្ម និងតម្លៃស្នូល
- ស្លាកសញ្ញារបស់ ហ្វូតាបា

# ទិដ្ឋភាពសង្ខេបរបស់ ហ្វូតាបា

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលសុី បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននាចុងឆ្នាំ២០១៥ ដែលបានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ពីធនាគារជាតិនៃកម្ពុជា ក្រោមបេសកកម្ម និងទស្សនៈវិស័យដ៏ច្បាស់លាស់របស់ខ្លួន ដែលចង់ក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជាផងដែរ។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតបន្តសុពលភាពអាជ្ញាបណ្ណជូនគ្រឹះស្ថាន **ហ្វូតាបា** រយៈពេល ៣ឆ្នាំបន្ថែមទៀត ក្រោយមកដោយមើលឃើញពីប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទាន និងបានកែសម្រួលលើចំណុចខ្វះខាតតាមអនុសាសន៍នៃការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន **ហ្វូតាបា**។ ចាប់តាំងពីឆ្នាំ២០១៦ ក្រុមហ៊ុន AZUMA & CO., LTD. (ជាក្រុមហ៊ុនជប៉ុន) ក៏បានក្លាយជាភាគទុនិកកាន់កាប់ភាគហ៊ុន ១00% របស់គ្រឹះស្ថាន **ហ្វូតាបា**។

បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ យើងមានបុគ្គលិកសរុបចំនួន ៩0នាក់ ស្ត្រីចំនួន ២៦នាក់ និងបុរសចំនួន ៦៤នាក់ ដែលកំពុងបម្រើការងារនៅការិយាល័យកណ្តាល និងសាខាចំនួន 0៤ ខេត្ត-រាជធានីរួមមាន សាខាការិយាល័យកណ្តាល សាខាខណ្ឌព្រែកព្នៅ/ទួលគោក សាខាខណ្ឌពោធិ៍សែនជ័យ និងសាខាក្រុងច្បារមន ចំពោះអតិថិជនដែលបាន និងកំពុងទទួលកម្ចីមានសរុប ៧៨៩នាក់ ជាមួយនឹងផលបត្រឥណទានសរុប ១៣.២៩៥.៩២០ ដុល្លារអាមេរិក ក្រោមការគ្រប់គ្រងមន្ត្រីឥណទានចំនួន ២៦នាក់ ដែលលទ្ធផលជារួមមានធ្លាក់ចុះតិចតួចលើផលបត្រឥណទាន និងកើនឡើងលើចំនួនអតិថិជន តែគ្រឹះស្ថាន **ហ្វូតាបា** នៅតែបន្តដំណើររបស់ខ្លួនប្រកបដោយវិជ្ជមានទៅថ្ងៃអនាគត។ ជាពិសេសក្នុងអំឡុង ៤ឆ្នាំកន្លងមកពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ យើងបានរក្សាកម្រិតហានិភ័យនៃផលបត្រឥណទានក្នុងអត្រា 0.៤៦% និងអតិថិជនឃឹតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា 0% ដែលនេះជាលទ្ធផលមួយដ៏ល្អប្រសើរលើការគ្រប់គ្រងឥណទានដែលយើងបានបញ្ចេញនៅក្នុងឆ្នាំនីមួយៗ ដោយឡែកចាប់តាំងពីឆ្នាំ២០២០ មកដល់ពេលនេះ មានការកើនឡើងលើកម្រិតហានិភ័យនៃផលបត្រឥណទានជាបន្តបន្ទាប់ផងដែរ ដោយក្នុងឆ្នាំ២០២២ មានកម្រិតហានិភ័យនៃផលបត្រឥណទានក្នុងអត្រា ១២,៦២% ហើយអតិថិជនឃឹតយ៉ាវដែលត្រូវលុបចេញពីបញ្ជីក្នុងអត្រា 0,0៣% ដោយសារតែមានផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដមិនទាន់បញ្ចប់។ ក្នុងស្ថានភាពនេះផងដែរ គ្រឹះស្ថាន **ហ្វូតាបា** បាននិងកំពុងផ្តល់ឥណទានរៀបចំឡើងវិញជូនអតិថិជនក្នុងអត្រា 0.៦៣% បើធៀបនឹងអតិថិជនសរុប និងអត្រា 0.៩៥% បើធៀបនឹងផលបត្រឥណទានសរុប។

ចំពោះរបាយការណ៍ហិរញ្ញវត្ថុវិញ យើងឃើញថា គ្រឹះស្ថាន **ហ្វូតាបា** បានចំណាយពេលវេលាជាង ១ឆ្នាំ ទើបទទួលបានការចំណេញសុទ្ធរបស់ខ្លួនចាប់តាំងពីឆ្នាំ២០១៧ រហូតមក ហើយទោះបីមានផលប៉ះពាល់ច្រើនពីការរីករាលដាលនៃមេរោគកូវីដ ចាប់តាំងពីឆ្នាំ២០១៩ មកយ៉ាងណាក៏ដោយក៏ការចំណេញសុទ្ធនៅបំណាច់ឆ្នាំ២០២២ នេះមានចំនួន ៤៤៩.៤២៦ ដុល្លារអាមេរិក ជាមួយនឹងទ្រព្យសកម្មចំនួន ១៥.៧៤៣.៧៨0 ដុល្លារអាមេរិក ដែលជាលទ្ធផលហិរញ្ញវត្ថុដ៏ល្អប្រសើរមួយក្នុងស្ថានភាពដែលលំបាក ហើយគ្រឹះស្ថាននៅតែបន្តប្រតិបត្តិការសកម្មភាព អាជីវកម្មរបស់ខ្លួនប្រកបដោយវិជ្ជមាន។

ជាផ្នែកមួយក្នុងការគាំទ្រដល់ការអភិវឌ្ឍលើការអប់រំ និងជីវភាពរបស់បុគ្គលិក គ្រឹះស្ថាន **ហ្វូតាបា** ក៏បានផ្តល់ឥណទានក្នុងអត្រាការប្រាក់ទាបបំផុតលើឥណទានសិក្សា និងឥណទានបុគ្គលិក ដែលជាគោលដៅចម្បងរបស់ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគទុនិក ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីភាពវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** នឹងបន្តអនុវត្តផែនការគោល ផែនការរំកិលប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្ររយៈពេលវែងរបស់ខ្លួន ដោយគ្រោងនឹងបង្កើតសាខាថ្មីមួយបន្ថែមទៀតនៅខេត្តតាកែវក្នុងឆ្នាំ២០២៣ ខាងមុខ ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារឱ្យបានទូលំទូលាយ និងឆ្លើយតបទៅនឹងកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់ និងការរីកចម្រើនរបស់ប្រទេសនាពេលបច្ចុប្បន្ន និងអនាគត។

## ប្រវត្តិសង្ខេបរបស់គ្រឹះស្ថាន ហ្វូតាបា

គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ត្រូវបានបង្កើតឡើងស្របតាមគោលបំណង និងក្តីសុបិនរបស់ភាគទុនិកតាមរយៈគំនិតផ្តួចផ្តើម ព្រមទាំងការប្តេជ្ញាចិត្តខ្ពស់ ភាគទុនិកបានជម្នះនូវរាល់ឧបសគ្គទាំងឡាយរហូតទទួលបានអាជ្ញាបណ្ណជាផ្លូវការពីធនាគារជាតិនៃកម្ពុជា លេខ ម.ហ-៦៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥។

នៅដើមឆ្នាំ២០១៦ គ្រឹះស្ថានក៏ចាប់ផ្តើមប្រតិបត្តិការអាជីវកម្មជាមួយនឹងដើមទុនដំបូង ១.000.000 ដុល្លារអាមេរិក ដោយទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនជាច្រើន ដែលបង្ហាញពីភាពជោគជ័យដ៏ត្រចះត្រចង់។ ជាមួយគ្នានេះផងដែរ ក្នុងឆ្នាំ២០១៦ នេះ ក្រុមហ៊ុន AZUMA & CO., LTD. ក៏បានក្លាយជាភាគទុនិកថ្មីរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។ ក្រុមហ៊ុន AZUMA & CO., LTD. ជាក្រុមហ៊ុនជប៉ុន ដែលមានគោលគំនិតស្របគ្នាក្នុងការគាំទ្រលើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មី តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។

ស្របតាមចក្ខុវិស័យរយៈពេលវែង និងការរំពឹងទុកអំពីវិជ្ជមាននៃវឌ្ឍនភាពទីផ្សារហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី នឹងបន្តអនុវត្តផែនការគោលរបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវវត្ថុបំណងនៃក្តីសុបិនរបស់ភាគទុនិក។ ជាក់ស្តែងគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានបង្កើតការិយាល័យសាខាថ្មីចំនួនបី (៣) បន្ថែមទៀតនៅចុងឆ្នាំ២០១៦ នេះ ដើម្បីពង្រីកនូវសក្តានុពលរបស់ខ្លួនគ្របដណ្តប់លើវិសាលភាពទីផ្សារទូលំទូលាយ និងឆ្លើយតបទៅតាមកំណើននៃតម្រូវការឥណទានពីសំណាក់អតិថិជនក្នុងតំបន់។ សាខាបើកថ្មីទាំងបី (៣) នោះ ត្រូវបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦។ ដោយមើលឃើញពីដំណើរការជាវិជ្ជមាននៃការប្រតិបត្តិ និងការគ្រប់គ្រងព្រមទាំងផែនការយុទ្ធសាស្ត្រវែងឆ្ងាយទៅថ្ងៃអនាគតរបស់គ្រឹះស្ថាន **ហ្វូតាបា** កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានផ្តល់សុពលភាពអាជ្ញាប័ណ្ណរយៈពេល ៣ឆ្នាំ បន្ថែមទៀត ហើយនាចុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជា បានសម្រេចផ្តល់អាជ្ញាបណ្ណអចិន្ត្រៃយ៍ប្រកបអាជីវកម្មជាផ្លូវការជូនគ្រឹះស្ថាន **ហ្វូតាបា** កាលពីថ្ងៃទី៣0 ខែធ្នូ ឆ្នាំ២០១៩។ យើងឃើញថា គ្រឹះស្ថាន **ហ្វូតាបា** មិនមានការបន្ថែមដើមទុន និងពង្រីកប្រតិបត្តិការសាខាទៀតទេចាប់ពីឆ្នាំ២០១៧ មកដល់ឆ្នាំ២0២២ នេះ ដោយសារតែគ្រឹះស្ថាននៅរក្សាយុទ្ធសាស្ត្រក្នុងការពង្រឹងលើប្រព័ន្ធនៃការត្រួតពិនិត្យផ្ទៃក្នុង និងបង្កើនចំណេះជំនាញដល់បុគ្គលិក ជាពិសេសខិតខំប្រឹងប្រែងរក្សាលទ្ធផលរបស់ខ្លួនឱ្យបានល្អប្រសើរក្នុងស្ថានភាព ដែលរងផលប៉ះពាល់នៃមេរោគកូវីដកន្លងមក និងបញ្ហាសង្គ្រាមរវាង ប្រទេសអ៊ុយក្រែន និងរុស្ស៊ី។ ហើយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២0២២ គ្រឹះស្ថាន **ហ្វូតាបា** មានប្រតិបត្តិការអាជីវកម្មមានរយៈពេល ៧ឆ្នាំមកហើយ ដែលមានទីតាំងកំពុងបម្រើសេវាអតិថិជនចំនួន 0៤ ខេត្ត/រាជធានី រួមមាន ការិយាល័យកណ្តាល (សាខាការិយាល័យកណ្តាល) សាខាខណ្ឌព្រែកព្នៅ/ខណ្ឌទួលគោក សាខាខណ្ឌពោធិ៍សែនជ័យ និងសាខាក្រុងច្បារមន។

## ដើមទុន

| ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ | ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ | ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ |
|---|---|---|
| ដើមទុនដំបូងចំនួន **១.000.000 ដុល្លារអាមេរិក** | បន្ថែមដើមទុនចំនួន **១.000.000 ដុល្លារអាមេរិក** | បន្ថែមដើមទុនចំនួន **៥.000.000 ដុល្លារអាមេរិក** |

## ការវិវឌ្ឍន៍នៃដើមទុន



# ទស្សនៈវិស័យ បេសកកម្ម និងតម្លៃស្នូល

## ទស្សនៈវិស័យ និងបេសកកម្ម

### ទស្សនៈវិស័យ

ជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយឲ្យល្អប្រសើរនូវកម្រិតជីវភាពរស់នៅរបស់អតិថិជននាពេលបច្ចុប្បន្ន និង អ្នកជំនាន់ថ្មី។

### បេសកកម្ម

ផ្ដល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលទុកចិត្តបំផុត ទៅកាន់ សហគ្រាស ខ្នាតមធ្យម ខ្នាតតូច ខ្នាតតូចបំផុត និងរូបវន្តបុគ្គល ដោយបង្កើតនូវទីផ្សារដែលមានស្ថិរភាព ដើម្បីគាំទ្រទាំងអតិថិជននាពេលបច្ចុប្បន្ន និងអ្នកជំនាន់ថ្មី ព្រមទាំងចូលរួមក្នុងសកម្មភាពសង្គម ដើម្បីសម្រេចនូវគោលបំណង ឬ ក្ដីសុបិនរបស់ពួកគាត់ជាមួយអនាគតដ៏ប្រសើរ។

## តម្លៃស្នូល

- ០១ សុចរិតភាព
- ០២ មនុស្សជាតិ
- ០៣ ការតម្រង់ទិស
- ០៤ ការប្រកួតប្រជែង
- ០៥ សេចក្ដីក្លៀវក្លា

# ស្លាកសញ្ញារបស់ ហ្វូតាបា

## និមិត្តសញ្ញា និងអត្ថន័យ

និមិត្តសញ្ញាសម្គាល់នេះ គឺសំដៅលើត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចមួយ ដែលបែកពន្លកចេញពីស្រទាប់ដី។

ត្រួយនៃពន្លករបស់គ្រាប់ធញ្ញជាតិដ៏តូចនេះ អាចលូតលាស់ជាឈើដ៏ធំមួយដើមនាពេលអនាគត ដ៏ឆាប់រហ័ស គឺអាស្រ័យលើការខិតខំបីបាច់ថែទាំ និងដាក់ជីយ៉ាងល្អិតល្អន់របស់យើងទាំងអស់គ្នា។
ក្នុងន័យនេះ យើងខ្ញុំជាគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ប្រៀបបានទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុដ៏តូចមួយ ដែលទើបតែចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនលើវិស័យហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ហើយយើងខ្ញុំអាចអភិវឌ្ឍជាធនាគារឈានមុខមួយ ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគតខាងមុខ ដើម្បីផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាពខ្ពស់ ធានាឲ្យបាននូវស្ថិរភាព និងផ្តល់អនាគតដ៏ត្រចះត្រចង់ បម្រើជូនសាធារណៈជនទាំងអស់របស់គ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ឬ ក៏ធនាគារ ហ្វូតាបា ប្រៀបដូចជាត្រួយនៃពន្លកធញ្ញជាតិដ៏តូចរីកលូតលាស់ទៅជាដើមឈើដ៏ធំនាពេលអនាគតដ៏ខ្លីខាងមុខ។

គ្រឹះស្ថានយើងខ្ញុំអាចអភិវឌ្ឍឆាប់រហ័សប្រៀបដូចនឹងដើមឈើដ៏ធំ គឺអាស្រ័យលើបុគ្គលិកគ្រប់លំដាប់ថ្នាក់នីមួយៗនៃគ្រឹះស្ថាន ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ផងដែរ ហើយក៏ពឹងផ្អែកលើទំហំទុន ដែលគ្រឹះស្ថានទទួលបានពីភាគទុនិករបស់ខ្លួន ដើម្បីបម្រើសេចក្តីត្រូវការរបស់អតិថិជនយើងខ្ញុំ។

## ពណ៌

ពណ៌បៃតងនៃត្រួយពន្លកគ្រាប់ធញ្ញជាតិ គឺសំដៅភាពយកចិត្តទុកដាក់លើបរិស្ថានភាព សុខដុម រវាងកំណើនសេដ្ឋកិច្ច និងនិរន្តរភាពបរិស្ថាននាពេលបច្ចុប្បន្ន និង តទៅអនាគតសម្រាប់ជំនាន់ក្រោយ។

## ពាក្យស្លោក

**សុបិនក្លាយជាការពិត**

# ០៣ អភិបាលកិច្ច

- ម្ចាស់ភាគទុនិក និងដើមទុន
- រចនាសម្ព័ន្ធ
- ក្រុមប្រឹក្សាភិបាល
- គណៈគ្រប់គ្រង

# ម្ចាស់ភាគទុនិក និងដើមទុន



## លោក Yosuke SASAKI
តំណាងភាគទុនិក




AZUMA & Co.,Ltd. ជាភាគទុនិកឯកកម្មសិទ្ធិកាន់កាប់លើភាគហ៊ុន ១០០ភាគរយ របស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី សូមសម្តែងនូវសុឆន្ទៈ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា។

AZUMA & Co.,Ltd. ជាសហគ្រាសជប៉ុនសុទ្ធសាធ ដែលរូបខ្ញុំ Yosuke SASAKI ជាជនជាតិជប៉ុន ទទួលកាន់កាប់លើភាគហ៊ុន ១០០ ភាគរយ និងមានតួនាទីជាប្រធាននាយក នៃសហគ្រាស AZUMA & Co.,Ltd.

យើងខ្ញុំមានកិត្តិយសក្រៃលែង ក្នុងនាមជានីតិបុគ្គលនៃសហគ្រាស AZUMA & Co.,Ltd. ដែលបានចូលរួមចំណែកក្នុងនាមជាអ្នកផ្តល់ហិរញ្ញប្បទាន និងថែរក្សាអ្នកជំនាន់ក្រោយក៏ដូចជាជួយលើកកម្ពស់កម្រិតស្តង់ដារ ការរស់នៅរបស់ពលរដ្ឋកម្ពុជាឲ្យកាន់តែប្រសើរឡើងៗ នៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគោលការណ៍ តម្លាភាព ប្រសិទ្ធភាព និងការផ្តល់សេវាហិរញ្ញប្បទាន ប្រកបដោយនិរន្តរភាពយូរអង្វែងរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី យើងខ្ញុំ។

# រចនាសម្ព័ន្ធ



ម្ចាស់ភាគហ៊ុនិក
ក្រុមប្រឹក្សាភិបាល
នាយកប្រតិបត្តិអភិបាល
ទីប្រឹក្សា នាយកប្រតិបត្តិ
គណៈកម្មាធិការ សវនកម្ម
គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
គណៈកម្មការ ឥណទាន
គណៈកម្មការ ប្រឹក្សាវិន័យ
គណៈកម្មការគ្រប់គ្រង ហានិភ័យព័ត៌មានវិទ្យា
គណៈកម្មការ ដឹកនាំអនុវត្តព័ត៌មានវិទ្យា
គណៈកម្មការ យុទ្ធសាស្ត្រព័ត៌មានវិទ្យា
ជំនួយការ នាយកប្រតិបត្តិ
ជំនួយការ នាយកប្រតិបត្តិ
នាយកដ្ឋានឥណទាន នាយក នាយកដ្ឋាន
នាយកដ្ឋានទីផ្សារ
នាយកដ្ឋានប្រតិបត្តិការ
នាយករង នាយកដ្ឋានប្រតិបត្តិការ
នាយកដ្ឋានហិរញ្ញវត្ថុ នាយិកា នាយកដ្ឋាន
នាយកដ្ឋានព័ត៌មានវិទ្យា នាយក នាយកដ្ឋាន
នាយកដ្ឋានធនធានមនុស្សរដ្ឋបាល នាយក នាយកដ្ឋាន
នាយកដ្ឋានច្បាប់ប្រតិបត្តិតាម នាយក នាយកដ្ឋាន
ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
ប្រធានផ្នែកឥណទាន
ប្រធានផ្នែកទីផ្សារ
ប្រធានផ្នែក ហិរញ្ញវត្ថុ
ប្រធានផ្នែក ព័ត៌មានវិទ្យា
ប្រធានផ្នែកធនធានមនុស្ស និងរដ្ឋបាល
មន្ត្រីវិភាគឥណទាន ជាន់ខ្ពស់
មន្ត្រីដោះស្រាយបំណុលជាន់ខ្ពស់
មន្ត្រីប្រតិបត្តិការ ជាន់ខ្ពស់
គណនេយ្យករជាន់ខ្ពស់
មន្ត្រីព័ត៌មានវិទ្យា ជាន់ខ្ពស់
មន្ត្រីសវនកម្មផ្ទៃក្នុង
មន្ត្រីប្រតិបត្តិការ
គណនេយ្យករ
មន្ត្រីព័ត៌មានវិទ្យា
មន្ត្រីធនធានមនុស្ស និងរដ្ឋបាល
អ្នកបើកបរ
សាខាការិយាល័យកណ្ដាល នាយកសាខា
សាខាខណ្ឌទួលគោក / សាខាខណ្ឌព្រែកព្នៅ នាយកសាខា
សាខាខណ្ឌពោធិ៍សែនជ័យ នាយកសាខា
សាខាក្រុងច្បារមន នាយកសាខា

# ក្រុមប្រឹក្សាភិបាល



**លោក ច្រឹក ផល្លី**
ប្រធានក្រុមប្រឹក្សាភិបាល

លោក **ច្រឹក ផល្លី** កើតនៅទីក្រុងភ្នំពេញ ឆ្នាំ១៩៨១ សញ្ជាតិខ្មែរ បានចាប់ផ្តើមការងារ ជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិបាល ក្រោយមកលោកត្រូវបាន តែងតាំង និងទទួលស្គាល់ជាប្រធានក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ រហូតមកដល់ពេលបច្ចុប្បន្ននេះ។ លោកមានបទពិសោធន៍ជាង ១៧ឆ្នាំ ខាងផ្នែកគ្រប់គ្រង ដែលក្នុងរយៈពេល ៥ឆ្នាំ លោកបានបំពេញតួនាទីជាប្រធានគ្រប់គ្រងផ្នែកទីផ្សារនៅក្រុមហ៊ុន Futaba Co., Ltd ក្នុងឆ្នាំ២០០៧ លោកត្រូវបានតែងតាំងជា នាយកចាត់ការទូទៅ ហើយបានបម្រើការងាររហូតមកដល់បច្ចុប្បន្ននេះ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រង ពាណិជ្ជកម្មពីសាកលវិទ្យាល័យន័រតុន។



**លោក យូសូកេ សាសាគី**
សមាជិកក្រុមប្រឹក្សាភិបាល

លោក **យូសូកេ សាសាគី** កើតនៅទីក្រុង KANAGAWA ប្រទេសជប៉ុន ឆ្នាំ១៩៨៣ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦។ ក្រុមហ៊ុន AZUMA & CO., LTD ជាក្រុមហ៊ុនជប៉ុន និងជាម្ចាស់ភាគហ៊ុន ១០០ ភាគរយ ដែលតំណាងពេញច្បាប់ដោយ លោក យូសូកេ សាសាគី មានតួនាទីជាប្រធាននាយក។ ក្រុមហ៊ុន AZUMA & CO., LTD. ជាក្រុមហ៊ុនជប៉ុន មានគោលគំនិតស្របគ្នាក្នុងការ គាំទ្រលើកស្ទួយកម្រិតជីវភាពស្តង់ដាររស់នៅជូនដល់ពលរដ្ឋកម្ពុជា ជាពិសេសចូលរួមអភិវឌ្ឍន៍មនុស្សជំនាន់ថ្មីតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយគុណភាព ស្ថិរភាព និងតម្លាភាពនៃទីផ្សារ។



**លោក ជូនីជី សាសាគី**
សមាជិកក្រុមប្រឹក្សាភិបាល

លោក **ជូនីជី សាសាគី** កើតនៅទីក្រុង KANAGAWA ប្រទេសជប៉ុន ឆ្នាំ១៩៤៩ សញ្ជាតិជប៉ុន ត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាលនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧។ លោក ជូនីជី សាសាគី បានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យតូក្យូ នៅឆ្នាំ១៩៧៥ បច្ចុប្បន្នជាប្រធាន និងជាភាគទុនិក ១00 ភាគរយ នៃក្រុមហ៊ុន FutureBud International Co., Ltd នៃប្រទេសជប៉ុន។



**លោក ម៉ូតូ ហាម៉ាដា**
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក **ម៉ូតូ ហាម៉ាដា** មានសញ្ជាតិជប៉ុន កើតនៅឆ្នាំ១៩៤៨ នៅទីក្រុង KANAGAWA ប្រទេសជប៉ុន។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សា ភិបាលឯករាជ្យ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សា ផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាល័យពាណិជ្ជកម្ម KOBE (មហាវិទ្យាល័យសេដ្ឋកិច្ច KOBE) ក្នុងឆ្នាំ ១៩៧0។ លោកមានបទពិសោធន៍ច្រើនជាង ១៥ឆ្នាំ ក្នុងការវិនិយោគក្រៅប្រទេស និង ២0ឆ្នាំសម្រាប់ការគ្រប់គ្រងក្រុមហ៊ុន ដែលមានសម្ព័ន្ធភាពនៅក្រៅប្រទេស និង ៥ឆ្នាំសម្រាប់ការពិគ្រោះយោបល់ និងជួយគម្រោងក្រៅប្រទេសរបស់ក្រុមហ៊ុនខ្នាតតូច និងមធ្យម។



**លោក ង៉ែត សុវណ្ណារ៉ូ**
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ

លោក **ង៉ែត សុវណ្ណារ៉ូ** មានសញ្ជាតិខ្មែរ កើតនៅឆ្នាំ១៩៥៩ ក្នុងខេត្តតាកែវ នៃប្រទេសកម្ពុជា។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកកសិកម្មពីសាកលវិទ្យាល័យមិត្តភាពនៃប្រជាជនម៉ូស្គូ នៃអាហារូបករណ៍ ផ្នែកអនុបណ្ឌិតផ្តល់ដោយរដ្ឋាភិបាលរុស្ស៊ីក្នុងឆ្នាំ ១៩៨៧។ លោកមានបទពិសោធន៍ ច្រើនជាង ២៥ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩២ ក្នុងមុខតំណែងប្រធានគណនេយ្យ និងរយៈពេល ៨ឆ្នាំ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋាន នៃក្រសួងផែនការ។

# គណៈគ្រប់គ្រង



**លោក ជូនីជី សាសាគី**
ប្រធាននាយកប្រតិបត្តិ

លោក **ជូនីជី សាសាគី** បានបញ្ចប់ការសិក្សា ពីសាកលវិទ្យាល័យតូក្យូ នៅក្នុងឆ្នាំ ១៩៧៥ បច្ចុប្បន្នជាប្រធាន និងជាភាគទុនិក ១០០ ភាគរយ នៃ FutureBud International Co.,Ltd. នៃ ប្រទេសជប៉ុន។



**បណ្ឌិត ចាប រតនា**
ទីប្រឹក្សានាយកប្រតិបត្តិ

បណ្ឌិត **ចាប រតនា** បានចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ក្នុងខែមករា ឆ្នាំ២០១៥ ជាទីប្រឹក្សាហិរញ្ញវត្ថុក្នុងស្រុក បន្ទាប់មកគាត់ក៏មកកាន់ តំណែងជា នាយករង នាយកប្រតិបត្តិ នៅខែតុលា ឆ្នាំ២០១៥។ គាត់បានបញ្ចប់ថ្នាក់ បណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម និងថ្នាក់អនុបណ្ឌិតគ្រប់គ្រងការអប់រំនៅសាកលវិទ្យាល័យ បៀលប្រាយ។ អស់រយៈពេលជាង ២៥ឆ្នាំ គាត់ទទួលបានបទពិសោធន៍ ការងារយ៉ាងច្រើនដូចជា អ្នកបកប្រែភាសា រដ្ឋបាល អ្នកគ្រប់គ្រងគំរោង និងជាអ្នកប្រឹក្សាយោបល់ក្នុងស្រុក ដែលមានទំនាក់ទំនងជាមួយនឹងមន្ត្រីគ្រប់លំដាប់ថ្នាក់ក្នុងក្រសួងគ្រប់ខេត្ត-ក្រុង រួមជាមួយនឹងដៃគូ អភិវឌ្ឍ អង្គការសហប្រជាជាតិ, IO, អង្គការក្រៅរដ្ឋាភិបាល, វិស័យឯកជន ក្នុងផ្នែក អភិវឌ្ឍផែនការថ្នាក់ជាតិ, ហិរញ្ញវត្ថុ ស្ថិតិ ការអប់រំ M&E, Health based UNTAC, WHO-Ministry of Health, and UN-Ministry of Planning.



**លោក ព្រាប កណ្ដឹង**
ជំនួយការនាយកប្រតិបត្តិ

លោក **ព្រាប កណ្ដឹង** បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុ ( Master of Business Specializing in Finance ) ពីសាកលវិទ្យាល័យ Charles Sturt University នៃប្រទេសអូស្ត្រាលី និងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកគណនេយ្យ នៅសាកល វិទ្យាល័យជាតិគ្រប់គ្រង។ លោកមានបទពិសោធន៍ការងារជាច្រើនឆ្នាំ ដែលពាក់ព័ន្ធទៅនឹងវិស័យធនាគារ និង ហិរញ្ញវត្ថុ ការសិក្សាក៏ដូចជាបទពិសោធន៍ការងារ បានធ្វើអោយគាត់មានការអភិវឌ្ឍន៍ ជាបន្តបន្ទាប់នូវភាពរីកចំរើននៃអាជីព ការងាររបស់គាត់។ មុនពេល គាត់ចូលរួមបំរើការងារជាមួយ **ហ្វូតាបា** លោកមានបទពិសោធន៍ការងារជាច្រើនពាក់ពន្ធ័ទៅ នឹងការគ្រប់គ្រងគណនេយ្យ ប្រឹក្សាយោបល់ផ្នែកគណនេយ្យ និងជានាយកនាយកដ្ឋាន ហិរញ្ញវត្ថុ និងគណនេយ្យ។ លោក បានចូលរួមជាមួយ ហ្វូតាបា នៅឆ្នាំ២០១៥ ដែលមានតួនាទីជានាយក នាយកដ្ឋានហិរញ្ញវត្ថុ។ នៅខែកក្កដា ឆ្នាំ២០១៦ លោក ត្រូវបានតែងតាំង តួនាទីជាជំនួយការនាយកប្រតិបត្តិ ដែលទទួលខុសត្រូវទៅលើនាយកដ្ឋានចំនួន បី ដូចជា នាយកដ្ឋាន ហិរញ្ញវត្ថុ នាយកដ្ឋានព័ត៌មានវិទ្យា និងនាយកដ្ឋានធនធានមនុស្ស និង រដ្ឋបាល។



**លោក អ៊ុំ ពិសិដ្ឋ**
ជំនួយការនាយកប្រតិបត្តិ

លោក **អ៊ុំ ពិសិដ្ឋ** បានចាប់ផ្ដើមអាជីពការងាររបស់លោកជាមួយ **ហ្វូតាបា** នៅចុងឆ្នាំ ២០១៥ ក្នុងតួនាទីជានាយក នាយកដ្ឋាន ឥណទាន បន្ទាប់មកនៅខែកក្កដា ឆ្នាំ២០១៦ លោកត្រូវបានតែងតាំងជាជំនួយការនាយកប្រតិបត្តិ ដែលត្រូវទទួលបន្ទុក គ្រប់ គ្រង និង មើលការខុសត្រូវលើនាយកដ្ឋានចំនួនបី គឺ នាយកដ្ឋានឥណទាន នាយកដ្ឋានប្រតិបត្តិការ និងនាយកដ្ឋានទីផ្សារ។ លោកបានបញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋ កិច្ច ទទួលបានសញ្ញាប័ត្រភាសាអង់គ្លេសថ្នាក់ IEAP ពីសាកលវិទ្យាល័យ បញ្ញាសាស្រ្តកម្ពុជា ហើយបានចូលរួមវគ្គបណ្ដុះ បណ្ដាលសន្និសិទ និងសិក្ខាសិលាជាច្រើនដែលទាក់ទងទៅនឹងការវិវឌ្ឍន៍វិស័យអចលនទ្រព្យ ការគ្រប់គ្រងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាដើម។ ចំពោះបទពិសោធន៍ការងារ លោកបានចំណាយពេលជាង ១៦ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ជាមួយ និងមុខតំណែងជាច្រើនដូចជា មន្ត្រីសាខា នាយកសាខា នាយកគ្រប់គ្រងតំបន់ នាយក-នាយកដ្ឋានប្រតិបត្តិការ នាយក-នាយកដ្ឋានទីផ្សារ និងទំនាក់ទំនង នាយកគ្រប់គ្រងឥណទាន នាយក នាយកដ្ឋានឥណទាន។ លោកក៏បានចំណាយពេល ជាង បីឆ្នាំ បម្រើការងារនៅវិស័យទូរគមនាគមន៍ផងដែរ។



## លោក លឹម សំបូរ

នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

លោក **លឹម សំបូរ** កើតនៅខែមិថុនា ឆ្នាំ១៩៨១ បានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៥ ក្នុងមុខតំណែងជានាយក នាយកដ្ឋានទីផ្សារ។ បន្ទាប់បម្រើការងាររយៈពេល ២ឆ្នាំ លោកត្រូវបានផ្លាស់ប្តូរមុខតំណែងជា នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ដោយទទួលខុសត្រូវក្នុងការគ្រប់គ្រងរៀបចំចាត់ចែង និងបង្កើតគោលនយោបាយ នីតិវិធីការងារនានាពាក់ព័ន្ធនឹងកិច្ចការ ធនធានមនុស្ស និងផ្នែករដ្ឋបាល។ នៅមុនពេលចាប់ផ្តើមអាជីពមួយនេះ លោកធ្លាប់មានបទពិសោធន៍រយៈពេលជាង ១៤ឆ្នាំ បម្រើការងារជាមួយធនាគារធំៗចំនួនពីររួមមាន ៖ ធនាគារបរទេសថ្នាក់តំបន់ និងធនាគារក្នុងស្រុកមួយ ដែលមានបណ្តាញប្រតិបត្តិការធំជាងគេផងដែរ។ ជាមួយបទពិសោធន៍ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ លោកធ្លាប់បានទទួលខុសត្រូវមុខងារដូចជា ប្រធានទំនាក់ទំនង ប្រធានផ្នែកឥណទាន ភតិសន្យា អនុប្រធានផ្នែក ឥណទាន និង តួនាទីជាច្រើនទៀតដែលលោកបានចំណាយពេលជាង ១០ឆ្នាំ ចូលរួមក្នុងសកម្ម ភាពជាច្រើននៃការលក់ជួរមុខ។ ដោយឡែក លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រពីសាកលវិទ្យាល័យបៀលប្រាយ ផ្នែកហិរញ្ញវត្ថុ និងធនាគារក្នុង ឆ្នាំ២០០៨។



## លោក គង់ សារ៉ាត់

នាយក នាយកដ្ឋានព័ត៌មានវិទ្យា

លោក **គង់ សារ៉ាត់** ជាជនជាតិខ្មែរ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងក្នុងឆ្នាំ២០១១ បញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកព័ត៌មានវិទ្យា និងផ្នែកអក្សរសាស្ត្រអង់គ្លេសផងដែរ។ ជាមួយនិងអតីតភាពការងារ លោកមានតួនាទីជាប្រធានគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា នៃធនាគារពាណិជ្ជធំមួយនៅកម្ពុជា ដែលទទួលខុសត្រូវលើផ្នែកប្រព័ន្ធធនាគារស្នូលប្រព័ន្ធ Card និង SWIFT ជាមួយនិងមុខជំនាញបច្ចេកទេសជាច្រើនដូចជាការរៀបចំដំណើរការប្រព័ន្ធធនាគារ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញ Network ប្រកបដោយសុវត្ថិភាព និងការរៀបចំគោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មានវិទ្យា។ នៅដើមឆ្នាំ ២០១៦ គាត់បានចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** ជានាយករងផ្នែកព័ត៌មានវិទ្យា ក្រោយមកបានរយៈពេល ៦ខែ បន្ទាប់ គាត់ត្រូវបានតំឡើងតួនាទីជានាយក នាយកដ្ឋានព័ត៌មានវិទ្យា។ គាត់ជាអ្នកចាប់ផ្តើមដំបូងក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធ Network រៀបចំមជ្ឈមណ្ឌលទិន្នន័យ មជ្ឈមណ្ឌលទិន្នន័យសង្គ្រោះបន្ទាន់ គោលនយោបាយគ្រប់គ្រងផ្នែកព័ត៌មាន វិទ្យា ក៏ដូចជាគោលនយោបាយសុវត្ថិភាពទិន្នន័យសម្រាប់គ្រឹះស្ថាន **ហ្វូតាបា** ចាប់តាំងពីការកកើតដំបូងនៃគ្រឹះស្ថាន។ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ គាត់មានបទពិសោធន៍ផ្នែកព័ត៌មានវិទ្យាជាង ១០ឆ្នាំមកហើយ។



**លោក ផុន សុធា**
នាយក នាយកដ្ឋានឥណទាន

លោក **ផុន សុធា** បានចូលបម្រើការងារនៅក្នុងគ្រឹះស្ថាន ហ្វូតាបា ចាប់ពីថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០១៧។ មុនពេលដែលគាត់ចូលបម្រើការងារនៅគ្រឹះស្ថាន **ហ្វូតាបា** លោកបានកាន់ការងារក្នុងតួនាទីជានាយក នាយកដ្ឋានឥណទាន អស់រយៈពេល ៧ ឆ្នាំជាប់គ្នា ក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា ក្នុងចន្លោះឆ្នាំ២០១០ ដល់ពាក់កណ្ដាលឆ្នាំ២០១៧។ ហើយនៅចន្លោះពីឆ្នាំ២០០៤ រហូតដល់ចុងឆ្នាំ២០១០ លោកជាបុគ្គលិករបស់គ្រឹះស្ថានខ្នាតមធ្យមមួយកន្លែង ដែលការងារដំបូងគាត់បានចូលបម្រើនៅទីនោះ គឺមានតួនាទីជាជំនួយការរដ្ឋបាល/ហិរញ្ញវត្ថុ គាត់ត្រូវបានតែងតាំងជាបន្តបន្ទាប់រហូតក្លាយជានាយកសាខាដ៏ឆ្នើមរបស់គ្រឹះស្ថានមួយនេះផងដែរ។ បើនិយាយពីប្រវត្តិនៃការសិក្សា លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងការអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យន័រតុនក្នុងឆ្នាំ២០១១ និងបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៤។ ក្នុងរយៈពេលជាង ១៤ឆ្នាំ កន្លងមកនេះ លោកបានចូលរួមវគ្គបណ្ដុះបណ្ដាល និង សិក្ខាសាលាជាច្រើនទាំងក្នុង និងក្រៅប្រទេស ដែលពាក់ព័ន្ធនឹងវិស័យគ្រឹះស្ថានហិរញ្ញវត្ថុ ធនាគារ វិស័យអចលនទ្រព្យ វិស័យធានារ៉ាប់រង និង ច្បាប់ការងារផ្សេងៗជាច្រើនទៀត។



**លោក ស ភារុំ**
នាយក នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម

លោក **ស ភារុំ** បានចូលបម្រើការងារក្នុងគ្រឹះស្ថាន **ហ្វូតាបា** ក្នុងតួនាទីជានាយករង នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧។ មុនពេលគាត់ ចូលបម្រើការងារនៅ **ហ្វូតាបា** លោកបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន ក្នុងតួនាទីចុងក្រោយ ជាប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម ហើយគាត់បានចាប់ផ្ដើមការងារក្នុងតួនាទីជាច្រើនជាមួយគ្រឹះស្ថាន ចម្រើន ដែលចាប់ផ្ដើមពី ខែកុម្ភៈ ឆ្នាំ២០០៩ ជាមន្ត្រីឥណទាន និងក្លាយជាមន្ត្រីសវនកម្មផ្ទៃក្នុង ក្នុងខែកុម្ភៈ ឆ្នាំ២០១០។ ក្រោយមក គាត់ត្រូវបានតែងតាំងជាប្រធានសាខា នៅខែវិច្ឆិកា ឆ្នាំ២០១០ និងប្ដូរទៅជាមន្ត្រីប្រតិបត្តិតាមជាន់ខ្ពស់ ក្នុងខែមិថុនា ឆ្នាំ ២០១២។ បន្ទាប់មក គាត់ក៏ត្រូវបានដំឡើងទៅជាប្រធានផ្នែកច្បាប់ និងប្រតិបត្តិតាម ក្នុងខែមិថុនា ឆ្នាំ២០១៣ និងជាប្រធាននាយកដ្ឋានច្បាប់ ក្នុងខែមករា ឆ្នាំ២០១៥ ហើយបានទទួលខុសត្រូវក្នុងតួនាទីចុងក្រោយជា ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យ និងនីតិកម្ម។ ហើយគាត់ក៏ធ្លាប់បម្រើការ ងារនៅសណ្ឋាគារ Feeling Home ជាអ្នកទទួលភ្ញៀវរយៈពេល ១ឆ្នាំ និងធ្វើការជាអ្នកស្ម័គ្រចិត្ត ជាមួយអង្គការទស្សនៈពិភពលោកនៅស្រុករយៈពេល ៤ឆ្នាំផងដែរ។ គាត់បានទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ផ្នែកនីតិឯកជន នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបរិញ្ញាបត្រផ្នែកគណនេយ្យ ពីសាកលវិទ្យាល័យធនធានមនុស្ស។ ក្នុងតួនាទី និងការទទួលខុសត្រូវនោះ គាត់មានបទពិសោធន៍ក្នុងតួនាទីផ្សេងៗគ្នារយៈពេល ៩ឆ្នាំ ក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។



**អ្នកស្រី ប៊ូ រតនា**
នាយិកា នាយកដ្ឋានហិរញ្ញវត្ថុ

អ្នកស្រី **ប៊ូ រតនា** កើតនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៨១ នៅទីក្រុងភ្នំពេញ។ អ្នកស្រី បានបញ្ចប់បរិញ្ញាប័ត្រពាណិជ្ជសាស្ត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីវិទ្យាស្ថានជាតិគ្រប់គ្រង។ នៅថ្ងៃ០១ ខែកក្កដា ឆ្នាំ២០១៦ អ្នកស្រីបានចាប់ផ្តើមចូលរួមបំរើការងារក្នុងគ្រឹះស្ថាន **ហ្វូតាបា** ដោយមានមុខងារជាប្រធានគណនេយ្យ។ បន្ទាប់ពីបម្រើការងារអស់រយៈពេល ជាងបីខែ អ្នកស្រីត្រូវបានតែងតាំងជានាយិកាស្តីទី នាយកដ្ឋានហិរញ្ញវត្ថុក្នុងថ្ងៃទី១១ ខែ តុលា ឆ្នាំ២០១៦។ អ្នកស្រីទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពលើគោលនយោបាយ នីតិវិធី ក៏ដូចជាសេចក្តីណែនាំផ្សេងៗ ដែលជាតម្រូវការសម្រាប់ នាយកដ្ឋានហិរញ្ញវត្ថុទាំងមូល។ ទន្ទឹមនឹងនេះ អ្នកស្រីបានចូលរួមសហការជាមួយធនាគារជាតិនៃកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ សវនកម្មឯករាជ្យ ក៏ដូចជាក្រសួងពាក់ព័ន្ធផ្សេងៗ ដែលមានការងារទាក់ទងនឹង នាយកដ្ឋានហិរញ្ញវត្ថុ។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ អ្នកស្រីត្រូវបានតម្លើងឋានៈជានាយិកា នាយកដ្ឋានហិរញ្ញវត្ថុ។ មុនពេលចូលរួមបំរើការងារជាមួយ **ហ្វូតាបា** អ្នកស្រីមានបទពិសោធន៍ ការងាររយៈពេល ៨ឆ្នាំ ជាប្រធានគណនេយ្យ នៅក្រុមហ៊ុន **ហ្វូតាបា**។ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ រហូតមកដល់បច្ចុប្បន្ន អ្នកស្រីមានបទពិសោធន៍ការងារជាង ១០ឆ្នាំ ក្នុងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ។



**លោក ហួយ គីមហ៊ាង**
នាយក នាយកដ្ឋានទីផ្សារ

លោក **ហួយ គីមហ៊ាង** បានចូលរួមជាមួយគ្រឹះស្ថាន **ហ្វូតាបា** ចាប់តាំងពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ក្នុងតួនាទីជា នាយក នាយកដ្ឋានភតិសន្យាហិរញ្ញវត្ថុ។ មុនពេល ចូលបម្រើការងារជាមួយគ្រឹះស្ថាន **ហ្វូតាបា** គាត់បានមានបទពិសោធន៍ច្រើនជាង ១០ឆ្នាំ ពាក់ព័ន្ធនឹងភតិសន្យាហិរញ្ញវត្ថុ មីក្រូហិរញ្ញវត្ថុ និងការស្រាវជ្រាវទីផ្សារ និងសង្គម ជាមួយនឹងស្ថាប័នស្រាវជ្រាវរបស់អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងក្រុមហ៊ុនសេវាកម្មទូទាត់ប្រាក់។ សម្រាប់ប្រវត្តិនៃការសិក្សា គាត់បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យន័រតុននៅក្នុងឆ្នាំ២០១០ និងបរិញ្ញាប័ត្រសេដ្ឋកិច្ចពាណិជ្ជកម្មពីសាកលវិទ្យាល័យជាតិ គ្រប់គ្រងក្នុងឆ្នាំ២០០៥។

# ០៤ ផលិតផល ហ្វូតាបា

- ឥណទានអាជីវកម្ម
- ឥណទានគេហដ្ឋាន
- ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន
- ឥណទានកសិកម្ម
- ឥណទានសិក្សា
- ឥណទានបុគ្គលិក
- ឥណទាននិយោជិត

### ឥណទានអាជីវកម្ម



- អតិថិជនគោលដៅ :
  អតិថិជនទូទៅ ដែលមានតម្រូវការសាច់ប្រាក់ សម្រាប់ចាប់ផ្តើម ឬ ពង្រីកអាជីវកម្ម ដើម្បីបង្កើន ប្រាក់ចំណេញ។
- ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
- ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ
- រយៈពេល : រហូតដល់ ១០ ឆ្នាំ

### ឥណទានគេហដ្ឋាន



- អតិថិជនគោលដៅ :
  អតិថិជនដែលមានតម្រូវការទិញផ្ទះ ឬ សាងសង់ ផ្ទះសម្រាប់ស្នាក់នៅ និងប្រកបរបរអាជីវកម្ម។
- ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
- ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ
- រយៈពេល : រហូតដល់ ១០ ឆ្នាំ

### ឥណទានសម្រាប់ប្រើប្រាស់



- អតិថិជនគោលដៅ :
  អតិថិជនទូទៅ ដែលមានតម្រូវការសាច់ប្រាក់ ដើម្បីទិញឧបករណ៍សម្ភារៈផ្សេងៗ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន។
- ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
- ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ
- រយៈពេល : រហូតដល់ ១០ ឆ្នាំ

### ឥណទានកសិកម្ម



- អតិថិជនគោលដៅ :
  អតិថិជនដែលមានមុខរបរកសិកម្ម ហើយត្រូវការសាច់ប្រាក់បន្ថែម ដើម្បីវិនិយោគ បម្រើការឲ្យផ្នែកកសិកម្មរបស់ខ្លួន។
- ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
- ទំហំឥណទាន : ២០០ ដុល្លារ - ២០០.០០០ ដុល្លារ
- រយៈពេល : រហូតដល់ ១០ ឆ្នាំ

### ឥណទានសិក្សា



- អតិថិជនគោលដៅ : សម្រាប់ឪពុក-ម្ដាយ ឬអាណាព្យាបាលរបស់សិស្ស-និស្សិត ទាំងឡាយណា ដែលមានឆន្ទៈខ្ពស់ក្នុងការចង់ឲ្យកូន ឬអ្នកនៅក្រោមបន្ទុក បន្តការសិក្សាកម្រិតឧត្តមសិក្សា ក្រោយពេលបញ្ចប់ការសិក្សានៅថ្នាក់វិទ្យាល័យ និងអ្នកដែលមានបំណងសិក្សារាល់វគ្គជំនាញឯកទេសក្នុងរយៈពេលខ្លី-វែងផ្សេងៗ។
- ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
- ទំហំឥណទាន : រហូតដល់ ២.០០០ ដុល្លារ
- រយៈពេល : រហូតដល់ ៥ ឆ្នាំ

### ឥណទានបុគ្គលិក



- អតិថិជនគោលដៅ :
  សម្រាប់តែបុគ្គលិក ហ្វូតាបា តែប៉ុណ្ណោះ ដែលត្រូវការសាច់ប្រាក់ដើម្បីគាំទ្រដល់ការរស់នៅប្រចាំថ្ងៃ។
- ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
- ទំហំឥណទាន : ២៤ ដង ឬ ៤៨ ដងនៃប្រាក់ខែមូលដ្ឋាន
- រយៈពេល : រហូតដល់ ១៥ ឆ្នាំ

### ឥណទាននិយោជិត



- អតិថិជនគោលដៅ :
  សម្រាប់បុគ្គលទូទៅដែលមានបំណងចង់ទិញ ម៉ូតូ សម្ភារៈប្រើប្រាស់ រៀបការ និងផ្សេងៗ តែក្នុងលក្ខខណ្ឌស្របច្បាប់។
- ប្រភេទរូបិយប័ណ្ណ : ប្រាក់រៀល និងដុល្លារ
- - ទំហំឥណទាន : រហូតដល់ ១០.០០០ ដុល្លារ
- រយៈពេល : រហូតដល់ ២ ឆ្នាំ

| លក្ខណៈសម្បត្តិរបស់អ្នកខ្ចី | ឯកសារតម្រូវ |
|---|---|
| - ជានីតិជនមានអាយុចាប់ពី ១៨ឆ្នាំ ទៅ ៦៥ឆ្នាំ<br>- មានទីលំនៅអចិន្ត្រៃយ៍ ស្ថិតក្នុងតំបន់ប្រតិបត្តិការរបស់ ហ្វូតាបា<br>- មានប្រវត្តិល្អនៅក្នុងសង្គម<br>- មានមុខរបរ ឬ អាជីវកម្មស្របច្បាប់<br>- មានទ្រព្យធានាត្រឹមត្រូវ | - អត្តសញ្ញាណប័ណ្ណ ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ សំបុត្រកំណើត ឬ លិខិតឆ្លងដែន . . .<br>- ឯកសារទ្រព្យធានា (ប្លង់រឹង ឬ ប្លង់ទន់)<br>- ឯកសារផ្សេងៗ ពាក់ព័ន្ធនឹងប្រភពចំណូល |

« គ្រឹះស្ថាន ហ្វូតាបា នឹងនៅតែបន្តបេសកម្មរបស់ខ្លួន ដើម្បីសម្រេចបាននូវចក្ខុវិស័យក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុដែលកាន់តែប្រសើរដល់អ្នក។ »



# ០៥ សមិទ្ធផលអាជីវកម្ម

- សមិទ្ធផលឥណទានតាមវិស័យ
- សមិទ្ធផលឥណទានតាមផលិតផល
- ចំណាត់ថ្នាក់ប្រភេទឥណទាន
- ចំណាត់ថ្នាក់ប្រភេទផលិតផល

# សមិទ្ធផលឥណទានតាមវិស័យ

## ចំនួនគណនី

| វិស័យ | ២០២០ | ២០២១ | ២០២២ |
| --- | --- | --- | --- |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៨ | ៣០ | ៤២ |
| ជំនួញ និងពាណិជ្ជកម្ម | ១២៨ | ១១០ | ១១១ |
| សំណង់ | ១០៣ | ៦៨ | ៥៧ |
| ការដឹកជញ្ជូន | ៤០ | ៣៥ | ៣៦ |
| សេវាកម្ម | ១៧ | ១៨ | ១៥ |
| ប្រើប្រាស់ក្នុងគ្រួសារ | ៤៩៤ | ៤៩០ | ៥២៨ |
| ប្រភេទផ្សេងៗទៀត | - | - | - |
| សរុប | ៨០០ | ៧៥១ | ៧៨៩ |

## ផលបត្រឥណទានសរុប

| វិស័យ | ២០២០<br>ដុល្លារអាមេរិក | ២០២១<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក |
| --- | --- | --- | --- |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២៨៥.៩១៩ | ៤២៤.៩៦៥ | ៦០២.៥០៦ |
| ជំនួញ និងពាណិជ្ជកម្ម | ២.៨៥៨.៨២៩ | ២.៤៨០.៣៥៨ | ២.៣៥៦.០៦៨ |
| សំណង់ | ១.៩៥៥.៧៣០ | ១.២៥៩.៣២១ | ៩២៣.០៨២ |
| ការដឹកជញ្ជូន | ៧៤៥.១៣៨ | ៦២៥.១២៥ | ៦៣២.៤៤៤ |
| សេវាកម្ម | ៥៧៦.០៦៨ | ៤៤៩.១៣២ | ៣៧៧.៣៦៥ |
| ប្រើប្រាស់ក្នុងគ្រួសារ | ៨.៣៨៧.៥៣៥ | ៨.១៤៨.៦៣៣ | ៨.៤០៤.៤៥៤ |
| ប្រភេទផ្សេងៗទៀត | - | - | - |
| សរុប | ១៤.៤០៩.២១៩ | ១៣.៣៨៧.៥៣៤ | ១៣.២៩៥.៩២០ |

# សមិទ្ធផលឥណទានតាមផលិតផល

## ចំនួនគណនី

| ផលិតផល | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|
| ឥណទានអាជីវកម្ម | ២២៥ | ១៩៩ | ១៨៤ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ២៣៩ | ២៧១ | ៣២៤ |
| ឥណទានកសិកម្ម | ២០ | ៣១ | ៤០ |
| ឥណទានគេហដ្ឋាន | ២៣៣ | ១៩៦ | ១៨៥ |
| ឥណទានបុគ្គលិក | ៤៣ | ៣៥ | ៣៣ |
| ឥណទានសិក្សា | ៣ | ៣ | ៣ |
| ឥណទាននិយោជិត | ៣៧ | ១៦ | ២០ |
| សរុប | ៨០០ | ៧៥១ | ៧៨៩ |

## ផលបត្រឥណទានសរុប

| ផលិតផល | ២០២០<br>ដុល្លារអាមេរិក | ២០២១<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក |
|---|---|---|---|
| ឥណទានអាជីវកម្ម | ៥.៣០៧.៥៧០ | ៤.២៥៧.៣៥៧ | ៣.៨៨៩.១២៤ |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ២.៨៨៣.១៩៨ | ៣.៦៣៣.០៧៣ | ៤.២២៣.៨៦៥ |
| ឥណទានកសិកម្ម | ២៩១.១៨៤ | ៤៦២.៣៩៧ | ៥៨២.៨២១ |
| ឥណទានគេហដ្ឋាន | ៥.៤៣២.០៧០ | ៤.៦០៧.២៧៣ | ៤.២៦៧.៨១៨ |
| ឥណទានបុគ្គលិក | ៤៤៦.៧៧៨ | ៤០២.៥៥០ | ២៦៥.៧៩៧ |
| ឥណទានសិក្សា | ១.៩២៥ | ៦៥០ | ៧៩២ |
| ឥណទាននិយោជិត | ៤៦.៤៩៤ | ២៤.០៥៤ | ៣៧.៤១៤ |
| សរុប | ១៤.៤០៩.២១៩ | ១៣.៣៨៧.៣៥៤ | ១៣.២៦៧.៦៣១ |

## ចំណាត់ថ្នាក់ប្រភេទឥណទាន

### ផលបត្រឥណទានសរុប

| ប្រភេទ | ២០២១<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | កំណើន (%) |
|---|---|---|---|
| ឥណទានខ្នាតតូចបំផុត | ២៣០.៩០៩ | ២៩៧.៦៣១ | ២២% |
| ឥណទានខ្នាតតូច | ៤.២៣២.៦៥១ | ៤.៤២២.៨១៦ | ៤% |
| ឥណទានខ្នាតមធ្យម | ៧.៨៧៦.៨៩៨ | ៧.៥៩៨.៣១៨ | (៤%) |
| ឥណទានខ្នាតធំ | ១.០៤៧.០៧៦ | ៩៧៧.១៥៦ | (៧%) |
| សរុប | ១៣.៣៨៧.៥៣៤ | ១៣.២៩៥.៩២០ | (១%) |

## ចំណាត់ថ្នាក់ប្រភេទផលិតផល

### ផលបត្រឥណទានសរុប

| ផលិតផល | ២០២១<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក | កំណើន (%) |
|---|---|---|---|
| ឥណទានអាជីវកម្ម | ៤.២៥៧.៣៥៧ | ៣.៨៩៧.៤១៦ | (៩%) |
| ឥណទានប្រើប្រាស់ផ្ទាល់ខ្លួន | ៣.៦៣៣.០៧៣ | ៤.២៣២.៨៧១ | ១៤% |
| ឥណទានកសិកម្ម | ៤៦២.៣៩៧ | ៥៨៤.០៦៣ | ២១% |
| ឥណទានគេហដ្ឋាន | ៤.៦០៧.២៧៣ | ៤.២៧៦.៩១៨ | (៨%) |
| ឥណទានបុគ្គលិក | ៤០២.៥៥០ | ២៦៦.៣៦៤ | (៥១%) |
| ឥណទានសិក្សា | ៦៥០ | ៧៩៣ | ១៨% |
| ឥណទាននិយោជិត | ២៤.០៥៤ | ៣៧.៤៩៤ | ៣៦% |
| សរុប | ១៣.៣៨៧.៣៥៤ | ១៣.២៩៥.៩២០ | (១%) |

# ០៦ ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

- ការបណ្តុះបណ្តាលខាងក្នុង
- ការបណ្តុះបណ្តាលខាងក្រៅ
- សិក្ខាសាលាប្រចាំឆ្នាំ

# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពបុគ្គលិក

ប្រសិទ្ធភាពនៃការបម្រើសេវាកម្មល្អ ជូនអតិថិជនគឺជាគុណសម្បត្តិគន្លឹះ ដែលស្ថាប័ននីមួយៗអាចទាក់ទាញអតិថិជនសក្តានុពលគាំទ្រអាជីវកម្មរបស់ខ្លួនកាន់តែច្រើនឡើងៗ។ ទន្ទឹមគ្នានេះដែរ សមត្ថភាពជំនាញ និងឥរិយាបថល្អរបស់បុគ្គលិកដើរតួនាទីស្នូលក្នុងការនាំយកផលិតផលទៅដល់ដៃអតិថិជន និងបង្កើនប្រៀបឈ្នះនៃការប្រកួតប្រជែងក្នុងទីផ្សារ។

យ៉ាងណាមិញក្នុងឆ្នាំ២០២២នេះ ថ្នាក់ដឹកនាំរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានរួមគ្នារៀបចំវគ្គបណ្តុះបណ្តាលជាច្រើនជូនបុគ្គលិក ដោយបានធ្វើការហ្វឹកហ្វឺនដល់បុគ្គលិកចូលថ្មីៗយ៉ាងទៀងទាត់ និងបុគ្គលិកកំពុងបម្រើការងារតាមផ្នែកជំនាញនីមួយៗផងដែរ ដើម្បីធានាថាបុគ្គលិកនីមួយៗ មានសមត្ថភាពបំពេញភារកិច្ចបានល្អ ឆ្លើយតបតាមតម្រូវការទីផ្សារជាក់ស្តែង ប្រកបដោយភាពច្បាស់លាស់ គ្រប់គ្រាន់ ទាន់ពេល។

- ការបណ្តុះបណ្តាលខាងក្នុង

ការរៀបចំវគ្គបណ្តុះបណ្តាលខាងក្នុងសម្រាប់ឆ្នាំ២០២២នេះ មានចំនួនសរុប ២៣លើក ដែលក្នុងនោះបុគ្គលិកចូលថ្មីត្រូវបានទទួលការហ្វឹកហ្វឺនជំនាញបានត្រឹមត្រូវ ច្បាស់លាស់ មុននឹងអនុញ្ញាតឱ្យទៅបំពេញភារកិច្ចនៅកន្លែងការងាររៀងៗខ្លួន។ ចំពោះបុគ្គលិកំពុងបម្រើការងារនៅតាមការិយាល័យសាខានីមួយៗ ក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមវគ្គបណ្តុះបណ្តាលទៀតទាត់ជាប្រចាំផងដែរ។



កម្រងរូបភាពការបណ្តុះបណ្តាលខាងក្នុង

## - ការបណ្តុះបណ្តាលខាងក្រៅ

ស្របតាមទិសដៅអភិវឌ្ឍន៍ប្រកបដោយចិរភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងពាក់ព័ន្ធនានាបានដាក់ចេញនូវបទបញ្ញត្តថ្មីៗ ឱ្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនឯកជនទាំងអស់ ចូលរួមអនុវត្តតាមឱ្យបានពេញលេញនូវកាតព្វកិច្ចរៀងៗខ្លួនជាបន្តបន្ទាប់។ បរិយាកាសប្រកួតប្រជែងក្នុងទីផ្សារតំណាទាន ដែលជាផលិតផលចំបងរបស់គ្រឹះស្ថាន ធនាគារ និងមីក្រូហិរញ្ញវត្ថុ បានជំរុញយ៉ាងខ្លាំងក្លាដល់ថ្នាក់ដឹកនាំនៃគ្រឹះស្ថាននីមួយៗប្រឹងប្រែងបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រតិបត្តិតាម ក៏ដូចជាបង្កើនសក្តានុពលនៃសមត្ថភាពបុគ្គលិកឱ្យកាន់តែរឹងមាំ អាចផ្តល់នូវទំនុកចិត្តខ្ពស់ជូនដល់អតិថិជនសក្តានុពលទូទៅ និងចាប់យកចំណែកទីផ្សារកាន់តែធំទូលាយ។ ទន្ទឹមគ្នានេះថ្នាក់ដឹកនាំរបស់ គ្រឹះស្ថាន **ហ្វូតាបា** បានខ្នះខ្នែងចាត់បញ្ជូនថ្នាក់គ្រប់គ្រង និងបុគ្គលិកជំនាញពាក់ព័ន្ធៗ ឱ្យចូលរួមវគ្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗដែលរៀបចំឡើងដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងគ្រឹះស្ថានសិក្សានានា ជាបន្តបន្ទាប់ផងដែរ។

ក្នុងអំឡុងឆ្នាំ២០២២នេះ ការចូលរួមវគ្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅខាងក្រៅ សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិកជំនាញរបស់គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានចំនួនសរុប ១៥លើក ដែលក្នុងនោះរួមមានការចូលរួមដោយផ្ទាល់ និងតាមរយៈអនឡាញ។




កម្រងរូបភាពការបណ្តុះបណ្តាលខាងក្រៅ

## - សិក្ខាសាលាប្រចាំឆ្នាំ

ដូចគ្នាទៅនឹងឆ្នាំមុនៗដែរ ថ្នាក់ដឹកនាំរបស់គ្រឹះស្ថាន **ហ្វូតាបា** បានយកចិត្តទុកដាក់វាយតម្លៃខ្ពស់ លើការខិតខំប្រឹងប្រែងរបស់បុគ្គលិកគ្រប់រូប ដែលបានចូលរួមយ៉ាងសកម្មបំពេញបេសកកម្មការងារទទួលបានលទ្ធផលល្អ។ ពោលគឺថ្នាក់ដឹកនាំបានចាត់ចែងឱ្យរៀបចំវគ្គសិក្ខាសាលាប្រចាំឆ្នាំជាលើកទី ៥ ក្នុងគោលបំណងជួបជុំ ក៏ដូចជាបង្ហាញជូនបុគ្គលិកទាំងអស់ ជ្រាបអំពីវឌ្ឍនភាពថ្មីៗនៃអាជីវកម្ម បញ្ហាប្រឈមនានា វិធីសាស្ត្រដោះស្រាយបញ្ហា និងផែនការសកម្មភាពរបស់ ហ្វូតាបា ឆ្ពោះទៅកាន់ជោគជ័យថ្មីៗបន្ថែមទៀត។ សិក្ខាសាលាឆ្នាំនេះ ត្រូវបានប្រារព្ធធ្វើឡើងនៅខេត្តព្រះសីហនុ ក្រោមប្រធានបទ «សិក្ខាសាលាបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២២ និងទិសដៅសម្រាប់អនុវត្តឆ្នាំបន្ទាប់»។ វគ្គមានចូលរួមដ៏ខ្ពង់ខ្ពស់ពីសំណាក់ លោកប្រធានក្រុមប្រឹក្សាភិបាល និងលោកទីប្រឹក្សានាយកប្រតិបត្តិ បានជំរុញលើកទឹកចិត្តបន្ថែមទៀតដល់ថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់ ព្រមទាំងញ៉ាំងឱ្យបរិយាកាសនៃអង្គពិធីទាំងមូលដំណើរការទៅដោយរលូន និងសប្បាយរីករាយបំផុត។












កម្រងរូបភាពសិក្ខាសាលាប្រចាំឆ្នាំ

# ០៧ ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

- ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម
- សវនកម្មផ្ទៃក្នុង

# ការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម

និយ័តករ ក្រុមហ៊ុនសវនកម្មឯករាជ្យ និងអ្នកពិគ្រោះយោបល់ ជាផ្នែកមួយនៃការត្រួតពិនិត្យលើប្រតិបត្តិការរបស់ស្ថាប័នពីខាងក្រៅ ដែលអាចបង្ហាញឱ្យឃើញថា គ្រឹះស្ថាន **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី មានចំណុចខ្វះខាត កំណត់ហានិភ័យកើតឡើងនានា និង កំណត់ច្បាស់ពីតម្រូវការរបស់ស្ថាប័នដែលត្រូវកែលម្អ។ ការគ្រប់គ្រងការប្រតិបត្តិតាម និងហានិភ័យ បានបន្តពង្រឹងការអនុវត្តផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាបា** ដោយផ្តោតលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានានៃការផ្តល់អាជ្ញាបណ្ណរបស់ធនាគារជាតិនៃកម្ពុជា និងការចុះបញ្ជីជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាបាននូវការពង្រីកអាជីវកម្ម និងប្រតិបត្តិការរបស់គ្រឹះស្ថាន ប្រកបដោយភាពត្រឹមត្រូវពេញលេញស្របតាមច្បាប់ បទបញ្ជាផ្ទៃក្នុង និងបទប្បញ្ញត្តិនានានៅក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។

សមាជិកក្រុមប្រឹក្សាភិបាល បានសម្រេចបង្កើតឱ្យមាននាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ដែលទទួលខុសត្រូវដោយនាយកនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម គឺដើម្បីធានាថា ការគ្រប់គ្រងហានិភ័យដែលអាចកើតឡើង និងការប្រតិបត្តិតាមរបស់គ្រឹះស្ថាន **ហ្វូតាបា** មានភាពច្បាស់លាស់ដោយត្រូវត្រួតពិនិត្យលើការគ្រប់គ្រងផ្ទៃក្នុងដើម្បីកំណត់អត្តសញ្ញាណ និងវាយតម្លៃលើហានិភ័យទាំងខាងក្នុង និងក្រៅដែលអាចមានការគំរាមកំហែង ឬផលប៉ះពាល់ដល់ប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាបា** និងធានាថាការអនុវត្ត នឹងនីតិវិធីត្រូវបានអនុវត្តបានពេញលេញស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា។ ក្រៅពីនេះលោកក៏ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុលោមទៅតាមគោលការណ៍ផ្ទៃក្នុង នីតិវិធី និងគោលការណ៍ណែនាំនានា ទាក់ទងនឹងការអនុវត្តច្បាប់របស់គ្រឹះស្ថានរួមមានការត្រួតពិនិត្យលើប្រសិទ្ធភាពនៃការប្រកាន់ខ្ជាប់នូវការអនុវត្តន៍លើគោលការណ៍ដែលមានស្រាប់ជាមួយនឹងបញ្ហានានាទាំងខាងក្នុង និងក្រៅពាក់ព័ន្ធនឹងការប្រតិបត្តិតាម និងការគ្រប់គ្រងហានិភ័យនៃការប្រតិបត្តិតាម។ ក្នុងគោលដៅវាស់វែង និងត្រួតពិនិត្យលើសមត្ថភាព និងបទពិសោធន៍ការងាររបស់អ្នកទទួលខុសត្រូវផ្នែកប្រតិបត្តិតាម បានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨។ បន្ថែមលើនោះទៀត នាយកដ្ឋានច្បាប់ និងប្រតិបត្តិតាមត្រូវទទួលខុសត្រូវត្រួតពិនិត្យលើការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលត្រូវរាយការណ៍ និងសហការប្រតិបត្តិការជាមួយនាយកដ្ឋានស៊ើបការណ៍ហិរញ្ញវត្ថុ របស់ធនាគារជាតិនៃកម្ពុជាផងដែរ។

### - គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

គ្រឹះស្ថាន បានបង្កើតឱ្យមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្នុងកម្រិតក្រុមប្រឹក្សាភិបាលដែលមានសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យជាប្រធាន។ នាយកនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ជាអ្នកសម្របសម្រួលដើម្បីពិភាក្សាអំពីរបាយការណ៍នៃការប្រតិបត្តិតាមជាមួយគ្រប់នាយកដ្ឋាន ឬគណៈគ្រប់គ្រង និងពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់ និងភាពពេញលេញនៃការវិភាគហានិភ័យប្រតិបត្តិតាមដែលតម្រូវដោយច្បាប់ប្បញ្ញត្តិនានា។ រាល់ហានិភ័យប្រតិបត្តិតាមសំខាន់ៗត្រូវបានបង្ហាញ និងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ត្រឡប់មកវិញក្នុងការប្រតិបត្តិតាម និងដោះស្រាយឱ្យបានទាន់ពេលវេលា។ បន្ថែមលើនេះទៀត នាយកនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម ក៏ជាសមាជិកនៃគណៈកម្មការក្នុងកម្រិត គណៈគ្រប់គ្រងដែលមាន គណៈកម្មការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា គណៈកម្មការយុទ្ធសាស្ត្រព័ត៌មានវិទ្យា និងគណៈកម្មការដឹកនាំអនុវត្តព័ត៌មានវិទ្យា ដើម្បីត្រួតពិនិត្យ និងអនុវត្តឱ្យបានត្រឹមត្រូវលើផ្នែកព័ត៌មានវិទ្យា។

### - ការប្រជុំ និងសមាជិកភាព

កិច្ចប្រជុំគណៈកម្មាធិការនេះត្រូវធ្វើឡើងយ៉ាងតិច ២ដងក្នុង១ឆ្នាំ ដែលមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់សមាជិក។

គណៈកម្មាធិការនេះ ត្រូវមានសមាជិកយ៉ាងតិច ៣នាក់។ សមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានសមាសភាពដូចខាងក្រោម៖



លោក ង៉ែត សុវណ្ណារ៉ូ
សមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ
(ប្រធាន)



លោក Yosuke SASAKI
សមាជិកក្រុមប្រឹក្សាភិបាល
(សមាជិក)



លោក Junichi SASAKI
នាយកប្រតិបត្តិ/អភិបាល
(សមាជិក)



លោក ព្រាប កណ្តឹង
ជំនួយការនាយកប្រតិបត្តិ
(កោះអញ្ជើញ)



លោក អ៊ុំ ពិសិដ្ឋ
ជំនួយការនាយកប្រតិបត្តិ
(កោះអញ្ជើញ)



លោក ស ភារុំ
នាយកនាយកដ្ឋានច្បាប់ និងប្រតិបត្តិតាម
(លេខាធិការ)

- ភារកិច្ច និងការទទួលខុសត្រូវ

- ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ច្បាប់ និងប្រតិបត្តិតាម ក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់
- ត្រួតពិនិត្យលើការធ្វើបច្ចុប្បន្នភាពជាប្រចាំនូវការវាយតម្លៃនៃមុខងារប្រតិបត្តិតាម ដែលតម្រូវដោយច្បាប់និងបទប្បញ្ញត្តិនានា
- ពិនិត្យជាប្រចាំនូវបញ្ជីត្រួតពិនិត្យការប្រតិបត្តិតាមផ្ទៃក្នុង ដើម្បីកំណត់ពីហានិភ័យប្រតិបត្តិតាម និងចាត់វិធានការ និងផែនការសកម្មភាពបន្ត ក្នុងការគ្រប់គ្រងហានិភ័យឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព
- ពិចារណា និងពិនិត្យលើរបាយការណ៍សវនកម្មដែលបានរកឃើញពាក់ព័ន្ធផ្នែកប្រតិបត្តិតាម និងហានិភ័យផ្នែកច្បាប់ ដែលកំពុងកើតមានឡើង និងផលប៉ះពាល់នានា
- ត្រួតពិនិត្យនៃការប្រតិបត្តិតាមប្រកបដោយប្រសិទ្ធភាពលើការអនុវត្តនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា
- ធានាថា ការបណ្តុះបណ្តាលចាំបាច់ត្រូវបានផ្តល់ជូនដល់គ្រប់បុគ្គលិក និងដើម្បីធានាឱ្យបាននូវការយល់ដឹងនៃសកម្មភាពប្រតិបត្តិតាម រួមទាំងការយល់ដឹងនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យក្នុងគ្រឹះស្ថាន
- ពិនិត្យ និងធានាលើការបង្កើត និងកែប្រែនូវនីតិវិធី និងគោលការណ៍ក្នុងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យក្នុងការតាមដាន និងវាយតម្លៃ លើការអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

## សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុង ត្រូវតែជាផ្នែកមួយឯករាជ្យក្នុងការត្រួតពិនិត្យ និងរាយការណ៍លើការអនុវត្តទូទៅរបស់ស្ថាប័ន។ ផ្នែកសវនកម្មផ្ទៃក្នុងរបស់គ្រឹះស្ថាន **ហ្វូតាបា** ត្រូវបានបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០១៧ ទទួលខុសត្រូវដោយប្រធានផ្នែកសវនកម្មផ្ទៃក្នុង ហើយត្រូវបានផ្លាស់ប្តូរ និងបានទទួលស្គាល់ជាថ្មីពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០។ ប្រធានផ្នែកសវនកម្មផ្ទៃក្នុង នឹងទទួលខុសត្រូវក្នុងការធ្វើសវនកម្មផ្ទៃក្នុង និងត្រួតពិនិត្យប្រតិបត្តិការនានានៅក្នុងគ្រឹះស្ថាន **ហ្វូតាបា** ដោយត្រូវអនុវត្តទៅតាមផែនការសវនកម្ម ធ្វើបច្ចុប្បន្នភាពកម្មវិធីសវនកម្ម និងផ្តល់ការបណ្តុះបណ្តាលបុគ្គលិក ដែលជាតម្រូវការចាំបាច់ដើម្បីបង្កើនគុណភាពសវនកម្មរបស់ខ្លួន។ តាមគោលការណ៍ និងផែនការរបស់សវនកម្មផ្ទៃក្នុងយ៉ាងហោចណាស់ ៣ដងក្នុង១ឆ្នាំ ត្រូវចុះធ្វើសវនកម្មនៅការិយាល័យសាខា និង ១ដងក្នុងមួយឆ្នាំតាមនាយកដ្ឋានសំខាន់ៗ។ ប្រធានផ្នែកសវនកម្មផ្ទៃក្នុងត្រូវត្រួតពិនិត្យរាល់ប្រតិបត្តិការរបស់គ្រឹះស្ថាន **ហ្វូតាបា** និងរាយការណ៍ដោយឯករាជ្យ និងដោយផ្ទាល់ទៅគណៈកម្មាធិការសវនកម្មផ្ទៃក្នុងក្នុងកម្រិតក្រុមប្រឹក្សាភិបាល។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២២ សវនកម្មផ្ទៃក្នុង ក៏បានរាយការណ៍នូវរបាយការណ៍សវនកម្មផ្ទៃក្នុងរបស់ខ្លួន ទៅសមាជិកក្រុមប្រឹក្សាភិបាលពីការអនុវត្តការងារ និងកំហុសឆ្គងនានានៃប្រតិបត្តិការគ្រឹះស្ថានរបស់គណៈគ្រប់គ្រង នាយកដ្ឋាន និងការិយាល័យសាខានីមួយៗ។

ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង គ្រឹះស្ថាន **ហ្វូតាបា** បានបង្កើតគណៈកម្មាធិការចំនួន ២ រួមមាន គណៈកម្មាធិការសវនកម្មផ្ទៃក្នុង និងគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។

- គណៈកម្មាធិការសវនកម្ម

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីធានាអភិបាលកិច្ចសាជីវកម្មប្រកបដោយសុវត្ថិភាព និងត្រូវផ្តល់អំណាចពិសេសចាំបាច់ដែលត្រូវបានកំណត់ក្នុងគោលការណ៍ ដើម្បីសម្រេចគោលដៅរបស់ខ្លួន។ អំណាចតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្មផ្ទៃក្នុងមានភាពទូលំទូលាយ និងគោរពតាមលក្ខខណ្ឌដូចមានកំណត់ក្នុងមាត្រា ១៣១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក៏ដូចជាមាត្រា ៨ នៃប្រកាសលេខ ធ៧-០៨-២១១ ស្តីពីអភិបាលកិច្ចរបស់ធនាគារ និងហិរញ្ញវត្ថុ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រធានគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ហើយក៏ត្រូវឆ្លើយនឹងសំណួរទាំងអស់ពីភាគទុនិកនៅក្នុងកិច្ចប្រជុំ។

- ការប្រជុំ និងសមាជិកភាព

កិច្ចប្រជុំគណៈកម្មាធិការសវនកម្មផ្ទៃក្នុង អាចប្រព្រឹត្តទៅបានក្នុងករណីមានការស្នើឡើងដោយប្រធាន ឬតាមសំណើរបស់សមាជិក ឬតាមសំណើរបស់សវនករផ្ទៃក្នុង ឬសវនករឯករាជ្យ (ខាងក្រៅ) ប្រសិនបើចាំបាច់។ សេចក្តីបញ្ជាក់ពីទីកន្លែង ពេលវេលា និងរបៀបវារៈកិច្ចប្រជុំដែលត្រូវពិភាក្សាត្រូវបញ្ជូនទៅកាន់គ្រប់សមាជិក និងអ្នកពាក់ព័ន្ធដែលត្រូវចូលរួមប្រជុំឱ្យបានយ៉ាងតិចណាស់មុន ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។ ឯកសារពាក់ព័ន្ធត្រូវផ្ញើទៅកាន់គ្រប់សមាជិក និង អ្នកចូលរួមផ្សេងទៀតក្នុងពេលជាមួយគ្នា។ កិច្ចប្រជុំវិសាមញ្ញអាចប្រព្រឹត្តទៅបាន តាមការពិនិត្យថាសមស្រប ប៉ុន្តែកិច្ចប្រជុំសាមញ្ញត្រូវធ្វើឡើងយ៉ាងតិច ២ (ពីរ) ដងក្នុង១ (មួយ) ឆ្នាំ គឺនៅក្នុងខែមិថុនា និងខែធ្នូនៃឆ្នាំនីមួយៗទៅតាមស្ថានភាពជាក់ស្តែង។ ជាក់ស្តែងក្នុងឆ្នាំ២០២២ កិច្ចប្រជុំគណៈកម្មាធិការនេះ បានប្រព្រឹត្តទៅតាមប្រព័ន្ធអេឡិចត្រូនិចបានចំនួន ២លើក ដែលលើកទី១ កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២២ និងលើកទី២ កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២។

គណៈកម្មាធិការត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដោយមានសមាជិកយ៉ាងតិចបំផុត ៣ រូប។ ប្រធាននៃគណៈកម្មាធិការនេះ គឺជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យរបស់ក្រុមហ៊ុន ហើយគ្រប់សមាជិកទាំងអស់ក៏ត្រូវតែមានភាពឯករាជ្យលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនផងដែរ។ សមាជិកគណៈកម្មាធិការសវនកម្មរួមមានដូចខាងក្រោម:

| | | |
|---|---|---|
| - លោក MOTOO HAMADA | ក្រុមប្រឹក្សាភិបាលឯករាជ្យ | ប្រធាន |
| - លោក JUNICHI SASAKI | នាយកប្រតិបត្តិ/អភិបាល | សមាជិក |
| - លោក ព្រាប កណ្តឹង | ជំនួយការនាយកប្រតិបត្តិ | កោះអញ្ជើញ |
| - លោក អ៊ុំ ពិសិដ្ឋ | ជំនួយការនាយកប្រតិបត្តិ | កោះអញ្ជើញ |
| - បុគ្គលិកទទួលបន្ទុក | ប្រធានផ្នែកសវនកម្មផ្ទៃក្នុង | សមាជិក/លេខាធិការ |

- ភារកិច្ច និងការទទួលខុសត្រូវ

- ពិនិត្យ និងអនុម័តទៅលើលក្ខខណ្ឌនៃកម្មវិធីសវនកម្មផ្ទៃក្នុង និងផែនការប្រចាំឆ្នាំ រួមទាំងគោលបំណង វិសាលភាព និងតារាងកាលវិភាគ
- ពិនិត្យមើលបញ្ហាទាំងឡាយណា ដែលអាចជះឥទ្ធិពលដល់ឯករាជ្យភាពរបស់សវនករផ្ទៃក្នុង
- ពិនិត្យ និងអនុម័តគោលការណ៍ និងនីតិវិធី
- ពិនិត្យមើលការរកឃើញ និងការតាមដានរបស់សវនករផ្ទៃក្នុង រួមទាំងចំណុចសំខាន់ៗ ដែលមិនយល់ស្របគ្នា រវាងគណៈគ្រប់គ្រង និងសវនករផ្ទៃក្នុងពាក់ព័ន្ធនឹងការត្រួតពិនិត្យ
- ធានាថាការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងបើកចំហរមានការចូលរួមក្នុងចំណោមគណៈកម្មាធិការសវនកម្ម សវនករឯករាជ្យ និងសវនកម្មខាងក្នុង
- ផ្តល់ឱ្យគណៈកម្មាធិការសវនកម្ម អាចចូលជួបសវនករផ្ទៃក្នុង និងប្រធានផ្នែក/នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុងដោយមិនមានការចូលរួមពីគណៈគ្រប់គ្រង
- ប្រាប់ពីការរំពឹងទុករបស់គណៈកម្មាធិការសវនកម្ម ទៅកាន់សវនករផ្ទៃក្នុងឱ្យបានដឹងជាលាយលក្ខណ៍អក្សរ
- ទទួល និងពិនិត្យមើលរបាយការណ៍របស់សវនករផ្ទៃក្នុង ពាក់ព័ន្ធនឹងគុណភាព និងភាពទាន់ពេលវេលាកំណត់
- ពិនិត្យដាមតានការអនុវត្តតាមអនុសាសន៍លើការរកឃើញរបស់សវនករផ្ទៃក្នុង
- តាមដាន និងពិនិត្យឡើងវិញនូវគុណភាពនៃការផ្តល់សេវាកម្មសវនកម្មផ្ទៃក្នុង
- វាយតម្លៃដំណើរការរបស់ក្រុមហ៊ុនដែលមាន ដើម្បីតាមដាន និងវាយតម្លៃប្រសិទ្ធភាពរបស់សវនករផ្ទៃក្នុង
- ពិនិត្យមើលការរៀបចំផែនការសកម្មភាពរបស់សវនកម្មផ្ទៃក្នុង សវកម្មឯករាជ្យ និងការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិតាម។

០៨

# របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ របស់សវនករឯករាជ្យ

- របាយការណ៍ក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលលម្អិត
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរសាច់ប្រាក់

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្សរីករាយក្នុងការដាក់ជូននូវរបាយការណ៍ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

### សកម្មភាពចម្បងៗ

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់កម្ចីដល់ដៃគូក្នុងស្រុកតាមរយៈការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងការិយាល័យផ្សេងៗទៀតតាមបណ្តាខេត្ត និងស្រុកក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលនៃប្រតិបត្តិការ

| | ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|
| ចំណេញសម្រាប់ការិយបរិច្ឆេទ | ៥៩៩.៣៥២ | ៥៩៩.៣៥២ |

### ភាគលាភ

ក្រុមប្រឹក្សាភិបាលពុំបានណែនាំឱ្យមានការទូទាត់ភាគលាភសម្រាប់បរិច្ឆេទបច្ចុប្បន្នទេ។

### ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅ ឬពីទុនបម្រុង និងសំវិធានធននៅក្នុងអំឡុងការិយបរិច្ឆេទលើសពីការបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

### ឥណទានពិបាកទារ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវឥណទានពិបាកទារ និងការធ្វើសំវិធានធនចំពោះឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយជឿជាក់ថាមិនមានឥណទានពិបាកទារ និងសំវិធានធនគ្រប់គ្រាន់ត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យការជម្រះចេញពីបញ្ជីនៃឥណទានពិបាកទារ ឬក៏សំវិធានធនចំពោះឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ត្រូវបានធ្វើឡើងជាសារវន្តឡើយ។

### ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្ត ដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលរំពឹងទុកនិងអាចលក់លើទីផ្សារ។

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវឡើយ។

### វិធីសាស្ត្រកំណត់តម្លៃ

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង បណ្តាលឱ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម ឬ បំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះឡើយ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានា ចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយចាប់តាំងពីចុងការិយបរិច្ឆេទនេះ ឬ

(២) បំណុលយថាហេតុណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងតាំងពីចុងការិយបរិច្ឆេទនេះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬ បំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសងក្នុងអំឡុងពេល១២ខែបន្ទាប់ពីថ្ងៃការិយបរិច្ឆេទដែលនឹង ឬអាចមានការប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន នៅថ្ងៃដល់កំណត់សងនោះទេ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នៅថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង ពាក់ព័ន្ធនឹងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យមានចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍របស់ក្រុមហ៊ុនមានកំហុសឆ្គងធ្ងន់ធ្ងរនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តដែលកើតចេញពីកត្តា ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ រហូតមកទល់នឹងថ្ងៃ ចេញរបាយការណ៍នេះ ពុំមានប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះទេ។

## ដើមទុន

ក្រុមហ៊ុនមិនបានបោះផ្សាយភាគហ៊ុនថ្មីនៅក្នុងអំឡុងការិយបរិច្ឆេទបច្ចុប្បន្នទេ។

ក្រុមហ៊ុនពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធជាភាគហ៊ុននៃក្រុមហ៊ុននាចុងការិយបរិច្ឆេទនេះទេ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបាននៅបម្រើការចាប់តាំងពីថ្ងៃចេញរបាយការណ៍ចុងក្រោយរួមមាន៖

| | |
|---|---|
| លោក ច្រឹក ផល្លី | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក យូសូកេ សាសាគី | អភិបាល |
| លោក ជូនីជី សាសាគី | អភិបាល |
| លោក ម៉ូតូ ហាម៉ាដា | អភិបាលឯករាជ្យ |
| លោក ង៉ែត សុវណ្ណារ៉ូ | អភិបាលឯករាជ្យ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុងពេល និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រុមហ៊ុនមិនបានចូលរួមជាភាគីក្នុងការរៀបចំណាមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឱ្យទទួលបាននូវផលប្រយោជន៍ផ្សេងៗតាមរយៈការទិញភាគហ៊ុន ឬប័ណ្ណបំណុលពីសាមីក្រុមហ៊ុន ឬគ្រឹះស្ថានដទៃទៀតឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃការិយបរិច្ឆេទកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងក្រុមហ៊ុន ឬ រវាងគ្រឹះស្ថានដែលសមាជិកក្រុមប្រឹក្សា-ភិបាលនោះជាសមាជិក ឬក៏រវាងក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអត្ថប្រយោជន៍ដ៏ទៃទៀត ដែលអាចកើតឡើងពីប្រតិបត្តិការទាំងនេះដូចដែលមានបង្ហាញនៅ កំណត់សម្គាល់លេខ ២៧ នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារកិច្ចធ្វើការបញ្ជាក់អះអាងថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ដើម្បីបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលនៃប្រតិបត្តិការព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ។ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

ក. ជ្រើសរើសគោលការណ៍គណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យបានជាប់លាប់។

ខ. អនុលោមទៅតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម ហៅកាត់ថា (“ស.រ.ហ.អ.ក.ស.ធ.ត.ម”) និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គ. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

ឃ. រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីសន្មតយ៉ាងសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដ៏ខ្លី និង

ង. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាព និងចូលរួមក្នុងការសម្រេចចិត្តសំខាន់ៗទាំងអស់ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការ ហើយត្រូវប្រាកដថាការសមេច្រចិត្តលើកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់លក្ខខណ្ឌតម្រូវខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី៩ ដល់ ៣៧ បានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលនៃប្រតិបត្តិការ ព្រមទាំងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

ចុះហត្ថលេខាជំនួសឱ្យក្រុមប្រឹក្សាភិបាល




លោក ច្រឹក ផល្លី
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិក **ហ្វូតាបា** មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ហ្វូតាបា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) រួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ព្រមទាំងរបាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំនេះ ព្រមទាំងសេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ ដែលមានបង្ហាញចាប់ពីទំព័រទី៩ ដល់ ៣៧។

តាមទស្សនៈរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងលទ្ធផលនៃប្រតិបត្តិការ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

## មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“ស.ស.អ.ក”)។ កាតព្វកិច្ចរបស់យើងខ្ញុំបានធ្វើតាមស្តង់ដារ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

## ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌

យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុន ស្របតាមក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) (“ក្រមសីលធម៌ IESBA”) របស់ក្រុមប្រឹក្សាភិបាលស្តង់ដារក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ ជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលទាក់ទងនឹងសវកម្មនៃរបាយការណហិរញ្ញវត្ថុរបស់យើងក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌ផ្សេងទៀតរបស់យើងស្របតាមតម្រូវការទាំងនេះ និងក្រមសីលធម៌ IESBA។

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន មានទំនួលខុសត្រូវនូវព័ត៌មានផ្សេងទៀត។ ព័ត៌មានផ្សេងៗរួមមានព័ត៌មានដែលមានក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនករឯករាជ្យយើងខ្ញុំទេ។
ាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនរួមបញ្ចូលព័ត៌មានផ្សេងៗហើយយើងមិនបានបង្ហាញពីទម្រង់នៃការសន្និដ្ឋានលើការធានាណាមួយឡើយ។ទាក់ទងជាមួយនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអាននូវព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗមានភាពមិនស្របជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬក៏ការយល់ដឹងរបស់យើងខ្ញុំទទួលបានពីការធ្វើសវនកម្ម ឬបើមិនដូច្នោះទេកំហុសឆ្គងជាសារវន្តត្រូវបានបង្ហាញ។ ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាព័ត៌មានផ្សេងៗមានកំហុសឆ្គងជាសារវន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍ពីការពិត តែយើងខ្ញុំមិនមានអ្វីដើម្បីរាយការណ៍ក្នុងករណីនេះទេ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពធុនតូច និងមធ្យម និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសក្នុងការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។
នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃទៅលើលទ្ធភាពប្រតិបត្តិការរបស់ក្រុមហ៊ុន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយធ្វើការបង្ហាញប្រសិនបើមានកត្តាដែលពាក់ព័ន្ធនឹងនិរន្តភាពនៃដំណើរការអាជីវកម្ម ហើយប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែបនិរន្តរភាព ប្រសិនបើក្រុមប្រឹក្សាភិបាលមិនមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយ ប៉ុន្តែត្រូវតែធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺដើម្បីទទួលបានអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍របស់សវនករឯករាជ្យដែលមានការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់ ប៉ុន្តែមិនអាចធានាថាមតិយោបល់របស់សវនកម្មអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែការពារនូវកំហុសឆ្គងជាសារវន្ត នៅពេលដែលវាកើតមានឡើងនោះទេ។

ភាពខុសឆ្គងដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានចាត់ទុកជាកំហុសឆ្គងជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្តុំ អាចមានឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់លើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ។
ជាផ្នែកមួយនៃសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តការវិនិច្ឆ័យដែលមានជំនាញវិជ្ជាជីវៈ និងរក្សាបាននូវការសង្ស័យដែលមានជំនាញវិជ្ជាជីវៈតាមរយៈការធ្វើសវនកម្ម។ យើងបានធ្វើ៖

- កំណត់ និងការវាយតម្លៃហានិភ័យកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាតើការក្លែងបន្លំ ឬ ការភ័ន្តច្រឡំ ហើយធ្វើការរៀបចំ និងអនុវត្តតាមនីតិវិធីសវនកម្មអាចឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ដើម្បីទទួលបាននូវភស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនរកឃើញកំហុសឆ្គងជាសារវន្តជាលទ្ធផលបណ្តាលមកពីការក្លែងបន្លំច្រើនជាងការភ័ន្តច្រឡំ ការក្លែងបន្លំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬការបំពាននៃការត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលត្រឹមត្រូវទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបង្ហាញមតិយោបល់លើប្រសិទ្ធិភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- វាយតម្លៃនូវភាពសមស្របនៃគោលការណ៍គណនេយ្យ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន និងកំណត់បង្ហាញពាក់ព័ន្ធដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល។
- ធ្វើសេចក្តីសន្និដ្ឋានលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពគណនេយ្យដែលគណៈគ្រប់គ្រងប្រើប្រាស់ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើជាភាពមិនមានច្បាស់លាស់ជាសារវន្តអាចកើតឡើង ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចសង្ស័យយ៉ាងខ្លាំងលើសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនមានច្បាស់លាស់ជាសារវន្តកើតឡើង យើងខ្ញុំត្រូវបានទាមទារការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនករឯករាជ្យរបស់ យើងខ្ញុំ ភ្ជាប់និងការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ប្រសិនបើការបង្ហាញទាំងនោះមិនត្រឹមត្រូវ នោះមតិយោបល់របស់យើងខ្ញុំនឹងកែប្រែ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់ថ្ងៃចេញរបាយការណ៍សវនករឯករាជ្យរបស់យើងខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចនឹងបង្កឱ្យក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពនៃដំណើរការអាជីវកម្មបាន។
- វាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញទាំងឡាយ រចនាសម្ព័ន្ធ និងមាតិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានកំណត់បង្ហាញព័ត៌មាន ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍នៅក្នុងលក្ខខណ្ឌមួយដែលបង្ហាញនូវទិដ្ឋភាពត្រឹមត្រូវដែរឬទេ។

យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាលពាក់ព័ន្ធនឹងបញ្ហាដទៃទៀតក៏ដូចជា ក៏ដូចជាវិសាលភាពដែលបានគ្រោងទុក និងការកំណត់ពេលវេលានៃការធ្វើសវនកម្ម និងការស្វែងរកការធ្វើសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ណាមួយលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលបានកត់សម្គាល់ក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាដទៃ

របាយការណ៍នេះ ត្រូវបានធ្វើឡើងសម្រាប់ភាគទុនិករបស់ក្រុមហ៊ុនតែប៉ុណ្ណោះ។ យើងខ្ញុំនឹងមិនទទួលខុសត្រូវ ចំពោះខ្លឹមសារនៃរបាយការណ៍នេះ សម្រាប់បុគ្គលផ្សេងទៀតឡើយ។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យករជំនាញផ្សេងទៀត ដែលរបាយការណ៍សវនកម្មបានចេញផ្សាយកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ ដែលបានចេញមតិយោបល់ពិត និងត្រឹមត្រូវចំពោះរបាយការណ៍ហិរញ្ញវត្ថុនោះ។

**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | កំណត់សម្គាល់ | ២០២២ ដុល្លារអាមេរិក | ២០២២ ពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ ពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ៨៨.២៣៤ | ៣៦៣.២៥៩ | ១៣១.៣១៣ | ៥៣៤.៩៦៩ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៧ | ៣៥៥.៧៤៧ | ១.៤៦៤.៦១០ | ៣៥៤.៤៨១ | ១.៤៤៤.១៥៦ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ១.៧២៦.៥៧៦ | ៧.១០៨.៣១៣ | ១.២០១.២៩៣ | ៤.៨៩៤.០៦៨ |
| ឥណទានទៅអតិថិជន | ៩ | ១៣.២៩៥.៩២០ | ៥៤.៧៣៩.៣០៣ | ១៣.៣៨៧.៥៣៤ | ៥៤.៥៤០.៨១៤ |
| គណនីត្រូវទទួលផ្សេងៗ | ១០ | ១៧៨.៩២២ | ៧៣៦.៦២២ | ១៧២.៤១១ | ៧០២.៤០២ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១១ | ៩៨.៣៨១ | ៤០៥.០៣៥ | ៨៤.០៦៤ | ៣៤២.៤៧៧ |
| **ទ្រព្យសកម្មសរុប** | | **១៥.៧៤៣.៧៨០** | **៦៤.៨១៧.១៤២** | **១៥.៣៣១.០៩៦** | **៦២.៤៥៨.៨៨៦** |

| | កំណត់សម្គាល់ | ២០២២ ដុល្លារអាមេរិក | ២០២២ ពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ ពាន់រៀល |
|---|---|---|---|---|---|
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | ១២ | ៥.១៤៧.១៨២ | ២១.១៩០.៩៤៨ | ៥.១៥៨.២៩៣ | ២១.០១៤.៨៨៦ |
| បុព្វប្រទានពីភាគហ៊ុនិក | ១៣ | ១.៣៩០.០០០ | ៥.៧២២.៦៣០ | ១.៣៩០.០០០ | ៥.៦៦២.៨៦០ |
| បំណុលពន្ធពន្យារ | ១៤ | ១២៧.១៤៤ | ៥២៣.៤៥២ | ៤៦.៩១១ | ១៩១.១១៥. |
| គណនីត្រូវបង់ផ្សេងៗ | ១៥ | ៧៩.០៤១ | ៣២៥.៤១១ | ១៥២.៣៩៤ | ៦២០.៨៥៤ |
| បំណុលពន្ធចរន្ត | | ៤០.០៣១ | ១៦៤.៨០៨ | ៧២.៥៤២ | ២៩៥.៥៣៦ |
| **បំណុលសរុប** | | **៦.៧៨៣.៣៩៨** | **២៧.៩២៧.២៤៩** | **៦.៨២០.១៤០** | **២៧.៧៨៥.២៥១** |

| | កំណត់សម្គាល់ | ២០២២ ដុល្លារអាមេរិក | ២០២២ ពាន់រៀល | ២០២១ ដុល្លារអាមេរិក | ២០២១ ពាន់រៀល |
|---|---|---|---|---|---|
| **មូលធន** | | | | | |
| ដើមទុន | ១៦ | ៧.០០០.០០០ | ២៨.០០០.០០០ | ៧.០០០.០០០ | ២៨.០០០.០០០ |
| ទុនបម្រុងតាមច្បាប់ | ១៧ | ៧៩៨.៧៤៩ | ៣.២៥៧.៨៨៨ | ៤៧៤.២៥២ | ១.៩៣១.៦៦៨ |
| ចំណេញរក្សាទុក | | ១.១៦១.៦៣៣ | ៤.៧២៤.៣០៨ | ១.០៣៦.៧០៤ | ៤.២១៣.៧២៤ |
| លម្អៀងនៃការបកប្រែរូបិយប័ណ្ណ | | - | ៩០៧.៦៩៧ | - | ៥២៨.២៤៣ |
| **មូលធនសរុប** | | ៨.៩៦០.៣៨២ | ៣៦.៨៨៩.៨៩៣ | ៨.៥១០.៩៥៦ | ៣៤.៦៧៣.៦៣៥ |
| **បំណុល និងមូលធនសរុប** | | **១៥.៧៤៣.៧៨០** | **៦៤.៨១៧.១៤២** | **១៥.៣៣១.០៩៦** | **៦២.៤៥៨.៨៨៦** |

# របាយការណ៍លទ្ធផល

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | | ២០២២ | | ២០២១ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ១៨ | ១.៨៨១.៤៤៧ | ៧.៦៨៩.៤៧៤ | ១.៨១៤.៣០១ | ៧.៣៨០.៥៧៦ |
| ចំណាយការប្រាក់ | ១៩ | ( ៩៨.០៥៨ ) | ( ៤០០.៧៦៣ ) | ( ១១៣.៤៨១ ) | ( ៤៦១.៦៤១ ) |
| ចំណូលការប្រាក់សុទ្ធ | | ១.៧៨៣.៣៨៩ | ៧.២៨៨.៧១១ | ១.៧០០.៨២០ | ៦.៩១៨.៩៣៥ |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាព | ២០ | ( ៥៧.៩៩៩ ) | ( ២៣៧.០៤២ ) | ( ២៦.៦៩៨ ) | ( ១០៨.៦០៧ ) |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២១ | ១៧០.៦៤២ | ៦៩៧.៤១៤ | ៦២.៥៤៦ | ២៥៤.៤៣៧ |
| ចំណាយបុគ្គលិក | ២២ | ( ៧៧៤.០៩២ ) | ( ៣.១៦៣.៧១៤ ) | ( ៧៧៨.៧០៧ ) | ( ៣.១៦៧.៧៨០ ) |
| ចំណាយរំលស់ | ២៣ | ( ២៥.៨៥៥ ) | ( ១០៥.៦៦៩ ) | ( ២៤.៦៦៤ ) | ( ១០០.៣៣៣ ) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៤ | ( ៥០៧.៧៤២ ) | ( ២.០៧៥.១៤២ ) | ( ៣៤៥.៩៣២ ) | ( ១.៤០៧.២៥២ ) |
| ចំណេញមុនបង់ពន្ធ | | ៥៨៨.៣៤៣ | ២.៤០៤.៥៥៨ | ៥៨៧.៣៦៥ | ២.៣៨៩.៤០០ |
| ចំណាយពន្ធ | ២៥ | ( ១៣៨.៩១៧ ) | ( ៥៦៧.៧៥៤ ) | ( ១២៨.៦៩៣ ) | ( ៥២៣.៥២៣ ) |
| ចំណេញសម្រាប់ការិយបរិច្ឆេទ | | ៤៤៩.៤២៦ | ១.៨៣៦.៨០៤ | ៤៥៨.៦៧២ | ១.៨៦៥.៨៧៧ |
| ចំណូលលម្អិតផ្សេងៗ សុទ្ធនៃពន្ធ | | | | | |
| ខ្ទង់គណនីដែលមិនបានបែងចែកឡើងវិញលើចំណេញ ឬខាត | | | | | |
| - ការបកប្រែរូបិយប័ណ្ណបរទេស | | - | ៣៧៩.៤៥៤ | - | ២៣៦.២៦៩ |
| ចំណូលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ | | ៤៤៩.៤២៦ | ២.២១៦.២៥៨ | ៤៥៨.៦៧២ | ២.១០២.១៤៦ |

# របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | ដើមទុន | | ទុនបម្រុងតាមច្បាប់ | | ចំណេញរក្សាទុក | | លម្អៀងនៃការបកប្រែរូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២១ | ៧.០០០.០០០ | ២៨.០០០.០០០ | ៣០០.៨៥៦ | ១.២២៦.២៩៣ | ៧៥១.៤២៨ | ៣.០៥៣.២២២ | - | ២៩១.៩៧៤ | ៨.០៥២.២៨៤ | ៣២.៥៧១.៤ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | ៤៥៨.៦៧២ | ១.៨៦៥.៨៧៧ | - | - | ៤៥៨.៦៧២ | ១.៨៦៥.៨៧៧ |
| ចំណូលលម្អិតផ្សេងៗ សុទ្ធនៃពន្ធ | - | - | - | - | | - | - | ២៣៦.២៦៩ | - | ២៣៦.២៦៩ |
| ចំណូលលម្អិតសរុប | - | - | - | - | ៤៥៨.៦៧២ | ១.៨៦៥.៨៧៧ | - | ២៣៦.២៦៩ | ៤៥៨.៦៧២ | ២.១០២.១៤៦ |
| ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនសរុប | - | - | ១៧៣.៣៩៦ | ៧០៥.៣៧៥ | (១៧៣.៣៩៦) | (៧០៥.៣៧៥) | - | - | - | - |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៧.០០០.០០០ | ២៨.០០០.០០០ | ៤៧៤.២៥២ | ១.៩៣១.៦៦៨ | ១.០៣៦.៧០៤ | ៤.២១៣.៧២៤ | - | ៥២៨.២៤៣ | ៨.៥១០.៩៥៦ | ៣៤.៦៧៣.៦៣៥ |
| ចំណេញក្នុងការិយបរិច្ឆេទ | - | - | - | - | ៤៤៩.៤២៦ | ១.៨៣៦.៨០៤ | - | - | ៤៤៩.៤២៦ | ១.៨៣៦.៨០៤ |
| ចំណូលលម្អិតផ្សេងៗ សុទ្ធនៃពន្ធ | - | - | - | - | - | - | - | ៣៧៩.៤៥៤ | - | ៣៧៩.៤៥៤ |
| ចំណូលលម្អិតសរុប | - | - | - | - | ៤៤៩.៤២៦ | ១.៨៣៦.៨០៤ | - | ៣៧៩.៤៥៤ | ៤៤៩.៤២៦ | ២.២១៦.២៥៨ |
| ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមច្បាប់ តំណាងឱ្យប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនសរុប | - | - | ៣២៤.៤៩៧ | ១.៣២៦.២២០ | (៣២៤.៤៩៧) | (១.៣២៦.២២០) | - | - | - | - |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៧.០០០.០០០ | ២៨.០០០.០០០ | ៧៩៨.៧៤៩ | ៣.២៥៧.៨៨៨ | ១.១៦១.៦៣៣ | ៤.៧២៤.៣០៨ | - | ៩០៧.៦៩៧ | ៨.៩៦០.៣៨២ | ៣៦.៨៨៩.៨៩៣ |

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ចំណេញមុនបង់ពន្ធ | ៥៨៨.៣៤៣ | ២.៤០៤.៥៥៨ | ៥៨៧.៣៦៥ | ២.៣៨៩.៤០០ |
| និយ័តកម្មះ | | | | |
| សំវិធានធនសម្រាប់ការខាតបង់ឱនភាព | ៥៧.៩៩៩ | ២៣៧.០៤២ | ២៦.៦៩៨ | ១០៨.៦០៧ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ២៥.៨៥៥ | ១០៥.៦៦៩ | ២៤.៦៦៤ | ១០០.៣៣៣ |
| ចំណាយការប្រាក់ | ៩៨.០៥៨ | ៤០០.៧៦៣ | ១១៣.៤៨១ | ៤៦១.៦៤១ |
| ទ្រព្យសម្បត្តិ និងបរិក្ខារដែលបានជម្រះចេញពីបញ្ជី | ៥.៧៦២ | ២៣.៥៤៩ | - | - |
| **ចំណូលប្រតិបត្តិការមុនពេលបម្រែបម្រួលដើមទុនបង្វិល** | ៧៧៦.០១៧ | ៣.១៧១.៥៨១ | ៧៥២.២០៨ | ៣.០៥៩.៩៨១ |
| បម្រែបម្រួលដើមទុនបង្វិល | | | | |
| ឥណទានទៅអតិថិជន | ៣៣.៧១៦ | ១៣៧.៧៩៧ | ៨២៤.៩០៦ | ៣.៣៥៥.៧១៨ |
| គណនីត្រូវទទួលផ្សេងៗ | (៦.៥១១) | (២៦.៦១០) | (៤១.៥៦៩) | (១៦៩.១០៣) |
| គណនីត្រូវបង់ផ្សេងៗ | (៧៣.៣៥៣) | (២៩៩.៧៩៣) | ៨៩.២០៥ | ៣៦២.៨៨៦ |
| សាច់ប្រាក់បានមកពីប្រតិបត្តិការ | ៧២៩.៨៦៩ | ២.៩៨២.៩៧៥ | ១.៦២៤.៧៥០ | ៦.៦០៩.៤៨២ |
| ការប្រាក់បានបង់ | (១០៩.១៦៩) | (៤៤៦.១៧៤) | (១១៤.៨៧២) | (៤៦៧.២៩៩) |
| ពន្ធលើប្រាក់ចំណូលបានបង់ | (៩១.១៩៥) | (៣៧២.៧១៤) | (៩៧.៦០០) | (៣៩៧.០៣៧) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ** | ៥២៩.៥០៥ | ២.១៦៤.០៨៧ | ១.៤១២.២៧៨ | ៥.៧៤៥.១៤៦ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារតំណាងឱ្យសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | (៤៥.៩៣៤) | (១៨៧.៧៣២) | (១.៦៦០) | (៦.៧៥៣) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ការសងប្រាក់កម្ចី តំណាងឱ្យសាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន | - | - | (៣៧០.៨២៩) | (១.៥០៨.៥៣២) |
| **កំណើនសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | ៤៨៣.៥៧១ | ១.៩៧៦.៣៥៥ | ១.០៣៩.៧៨៩ | ៤.២២៩.៨៦១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | ១.៣៣៧.៣១៨ | ៥.៤៤៨.២៣៤ | ២៩៧.៥២៩ | ១.២០៣.៥០៥ |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | - | ៧២.០១០ | - | ១៤.៨៦៨ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ | ១.៨២០.៨៨៩ | ៧.៤៩៦.៥៩៩ | ១.៣៣៧.៣១៨ | ៥.៤៤៨.២៣៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៨៨.២៣៤ | ៣៦៣.២៥៩ | ១៣១.៣១៣ | ៥៣៤.៩៦៩ |
| សមតុល្យនៅធនាគារជាតិ (មិនរួមបញ្ចូលប្រាក់តម្កល់តាមច្បាប់) | ៥.៧៤៧ | ២៣.៦៦០ | ៤.៤៨១ | ១៨.២៥៦ |
| សមតុល្យនៅធនាគារផ្សេងៗ | ១.៧២៦.៩០៨ | ៧.១០៩.៦៨០ | ១.២០១.៥២៤ | ៤.៨៩៥.០០៩ |
| | ១.៨២០.៨៨៩ | ៧.៤៩៦.៥៩៩ | ១.៣៣៧.៣១៨ | ៥.៤៤៨.២៣៤ |

# ដៃគូសហប្រតិបត្តិការណ៍

## ដៃគូ

## ម្ចាស់កម្ចី



# ឥណទាននិយោជិត

### អតិថិជនគោលដៅ

សម្រាប់បុគ្គលទូទៅដែលមានបំណងចង់ទិញ ម៉ូតូ សម្ភារៈប្រើប្រាស់ រៀបការ និងផ្សេងៗ តែក្នុងលក្ខខណ្ឌស្របច្បាប់។

### ប្រភេទរូបិយប័ណ្ណ

ប្រាក់រៀល និង ដុល្លារ

### ទំហំឥណទាន

៤០.០០០.០០០ រៀល
ឬ
១០.០០០ ដុល្លារ

### រយៈពេលសង

រហូតដល់ ២ ឆ្នាំ

. មិនតម្រូវឲ្យមានទ្រព្យដាក់បញ្ចាំ
. សេវាកម្មរហ័ស ប្រកបដោយទំនុកចិត្តខ្ពស់
. អត្រាការប្រាក់ទាប និងលក្ខខណ្ឌឥណទានងាយស្រួល

០៧០ ៣១៩ ៣៣៣

អាសយដ្ឋាន៖
អគារលេខ ៧៩៥ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ
០២៣ ២២៤ ៣៣៣
info@futabamfi.com.kh Futaba Microfinance Plc.